ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សន្និបាត

## បូកសរុបលទ្ធផលការងារ
## អប់រំ យុវជន និងកីឡា ខេត្តកំពង់ឆ្នាំង
## ឆ្នាំសិក្សា ២០១៦-២០១៧ និងទិសដៅ
## ឆ្នាំសិក្សា ២០១៧-២០១៨

ថ្ងៃទី២៥-២៦ ខែមករា ឆ្នាំ២០១៨

# របាយការណ៍សន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១៦-២០១៧ និងលើកទិសដៅការងារឆ្នាំសិក្សា២០១៧-២០១៨

## I. សេចក្តីផ្តើម

ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៥-២០១៧ ត្រូវបានបញ្ចប់ មន្ទីរអប់រំ យុវជន និងកីឡាខេត្តបានធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៥-២០១៧ និងលើកទិសដៅឆ្នាំ២០១៨-២០២០ ក្នុងគោលបំណង ពង្រឹងការអនុវត្តគោលនយោបាយអប់រំ យុទ្ធសាស្ត្រ និងកម្មវិធីដែលបានកំណត់ ព្រមទាំងអាទិភាពកំណែទម្រង់ទាំង១៥ចំណុច ។

ការពិនិត្យតាមដានការបំពេញការងារប្រចាំឆ្នាំគឺជាការងារដ៏មានសារៈសំខាន់ ដើម្បីតម្រង់ទិសការងារឱ្យសម្រេចបានគោលដៅដែលបានគ្រោងទុក។ ជាមួយគ្នានេះ ការរៀបចំសន្និបាតអប់រំ ជារៀងរាល់ឆ្នាំ បានផ្តល់ឱកាសឱ្យ អ្នកពាក់ព័ន្ធបានពិភាក្សាពិនិត្យ អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងការកំណត់ទិសដៅសម្រាប់អនុវត្តបន្ត និងជាមូលដ្ឋានក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ (AOP) និងផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ (BSP)

ក្នុងឆ្នាំសិក្សា២០១៦-២០១៧ កន្លងមកនេះ មន្ទីរអប់រំ យុវជន និងកីឡាបានសម្រេចលទ្ធផលចម្បងៗ រួមមាន ៖

## II. វឌ្ឍនភាព

### ១.លទ្ធផលរួមរបស់វិស័យអប់រំយុវជននិងកីឡា

#### ១.១វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូលនៃទិសដៅអាទិភាព ឆ្នាំ២០១៨-២០២០

សូចនាករស្នូល ដែលបានកំណត់នៅក្នុងឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៥-២០១៧ និងត្រូវបានពិនិត្យឡើងវិញជាប្រចាំឆ្នាំអំពីវឌ្ឍនភាពនៃការសម្រេចបានវត្ថុបំណងគោលនយោបាយអប់រំរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំះ

-កុមារអាយុ៥ឆ្នាំបានទទួលសេវាអប់រំកុមារតូចគ្រប់រូបភាពសម្រេចបាន៦៨.៦២% នៃចំនួនប្រជាជនអាយុ៥ឆ្នាំ កើន៥% ធៀបនឹងឆ្នាំសិក្សា២០១៦-២០១៧ បើធៀបនឹងចំណុចដៅ បច្ចុប្បន្នភាពESP 2015-2017 ៧១% លទ្ធផលអាចទទួលយកបាន។

-ចំនួនស្រុកដែលមានអត្រាត្រួតថ្នាក់នៅបឋមសិក្សាតិចជាង ឬស្មើ៧% សម្រេចបាន ៦ លើ ៨ក្រុង ស្រុក ធៀបនឹងឆ្នាំសិក្សា២០១៦-២០១៧កើន ១ស្រុក បើធៀបនឹងចំណុចដៅ បច្ចុប្បន្នភាព ESP 2015-2017 ៦ លើ ៨ក្រុង ស្រុកសម្រេចចំណុចដៅ។

-ចំនួនស្រុកដែលមានអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិយ៉ាងតិច៨០% សម្រេចបាន ៨ លើ ៨ក្រុង ស្រុក ធៀបនឹងឆ្នាំសិក្សា២០១៦-២០១៧ កើន ១ស្រុក បើធៀបនឹងចំណុចដៅបច្ចុប្បន្នភាពESP 2015-2017 ៧ លើ ៨ក្រុង ស្រុក សម្រេចចំណុចដៅ។

-អត្រាអក្ខរកម្មជនពេញវ័យអាយុ១៥ឆ្នាំឡើង សម្រេចបាន៩៨.២៨% ធៀបនឹងឆ្នាំ២០១៦ កើន ០.១១% បើធៀបនឹងចំណុចដៅ បច្ចុប្បន្នភាពESP 2015-2017៩៨.២៨% សម្រេចចំណុចដៅ ។

-វង្វាយតម្លៃតេស្តស្តង់ដាថ្នាក់ខេត្តថ្នាក់ទី៣ មុខវិជ្ជាភាសាខ្មែរ (ការអាន) និងគណិតវិជ្ជា មិនបានអនុវត្ត បើធៀបនឹងចំណុចដៅបច្ចុប្បន្នភាពESP 2015-2017៥០% មិនសម្រេចចំណុចដៅ ។

-ភាគរយគ្រូបឋមសិក្សាមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម្រេចបាន ៧៥% ធៀបនឹងឆ្នាំ២០១៦ ថយ៣% បើធៀបនឹងចំណុចដៅ បច្ចុប្បន្នភា ESP 2015-2017 ៧៥% សម្រេចចំណុចដៅ ។

-ភាគរយគ្រូកម្រិតមូលដ្ឋានមានសញ្ញាបត្របរិញ្ញាបត្រ សម្រេចបាន ២២.៥% ធៀបនឹងឆ្នាំ២០១៦កើន ១.៥% បើធៀបនឹងចំណុចដៅ បច្ចុប្បន្នភាពESP 2015-2017 ២៣% លទ្ធផលអាចទទួលយកបាន។

-ចំនួននាយកសាលារៀនបានបណ្តុះបណ្តាលការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលមិនបានអនុវត្តមូលហេតុ ក្រសួងអប់រំ យុវជន និងកីឡា មិនបានរៀបចំវគ្គបណ្តុះបណ្តាល ។

-ភាគរយទូទាត់ចំណាយថវិកាប្រចាំឆ្នាំ២០១៧ សម្រេចបាន ៩៧.៦% ធៀបនឹងឆ្នាំ២០១៦ថយចុះ ០.២% បើធៀបនឹងចំណុចដៅ បច្ចុប្បន្នភាពESP 2015-2017 ១០០% លទ្ធផលអាចទទួលយកបាន ។ (ឧបសម្ព័ន្ធទី១)

*រូបភាពទី១៖ ការសម្រេចសូចនាករស្នូល (ឧបសម្ព័ន្ធទី១)*



ក្នុងឆ្នាំសិក្សា២០១៧-២០១៨ មានសូចនាករស្នូលសរុប ៩ ស្មើនឹង ៩០% សម្រេចចំណុចដៅឆ្នាំសិក្សា២០១៧-២០១៨ បច្ចុប្បន្នភាព ESP 2015-2017 សូចនាករស្នូល ៣ ស្មើនឹង ៣០% លទ្ធផលអាចទទួលយកបាន និងសូចនាករស្នូល ៣ ស្មើនឹង ៣០% មិនសម្រេចចំណុចដៅនៅឡើយ ។

### ១.២ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំ ឆ្នាំសិក្សា ២០១៦-២០១៧

ទិសដៅសន្និបាតអប់រំប្រចាំឆ្នាំសិក្សា ២០១៦-២០១៧សរុបមាន ៧០ ជាលទ្ធផលអនុវត្តរួច ៦១ ស្មើនឹង ៨៧% កំពុងអនុវត្ត ៧ ស្មើនឹង ១០% និងមិនបានអនុវត្ត ២ ស្មើនឹង ៣% ទិសដៅដែលមិនបានអនុវត្ត មានយុវជនដែលបានបណ្តុះបណ្តាលសហគ្រិនភាព មូលហេតុ មិនមានថវិកាអនុវត្ត និង រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ មូលហេតុ មិនទាន់មានគោលការណ៍ណែនាំជាផ្លូវការ ។(ឧបសម្ព័ន្ធទី២)

*រូបភាពទី២ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំសិក្សា២០១៦-២០១៧*




### ១.៣ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧( AOP )

ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧ (AOP)របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត មានសកម្មភាពរងសរុប១៩៩ ក្នុងនោះបានអនុវត្តចប់ចំនួន ១៨៨ ស្មើនឹង ៩៤ % កំពុងអនុវត្តចំនួន គ្មាន និងមិនទាន់អនុវត្តចំនួន ១១ ស្មើនឹង ៦% សកម្មភាពរងមានការកើនឡើង ៣សកម្មភាព ក្នុងកម្មវិធីទី៤ កើន ២សកម្មភាព មូលហេតុ ឥណទានថ្មីទើបផ្ទេរពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងត្រីមាសទី៣ និងកម្មវិធីទី៥ កើន ១សកម្មភាព អនុកម្មវិធីទី៥.១៧.១ មូលហេតុ មានការគាំទ្រផ្តល់ថវិកាបន្ថែម ផ្នែកអភិវឌ្ឍសមត្ថភាព ពីអង្គការ UNICEF។

កម្មវិធីទី១ មានសកម្មភាពបានអនុវត្តចប់ ១៣០ ស្មើនឹង ៩៣% កំពុងអនុវត្ត គ្មាន និងមិនទាន់បានអនុវត្ត ១០ ស្មើនឹង ៧ % ។ កម្មវិធីទី៣ មានសកម្មភាពបានអនុវត្តចប់ ៩ ស្មើនឹង ១០០% កំពុងអនុវត្ត និង មិនទាន់អនុវត្ត គ្មាន ។ កម្មវិធីទី៤ មានសកម្មភាពបានអនុវត្តចប់ ១៥ ស្មើនឹង ១០០% កំពុងអនុវត្ត និងមិនទាន់អនុវត្ត គ្មាន ។ កម្មវិធីទី៥ មានសកម្មភាពបានអនុវត្តចប់ ៣៤ ស្មើនឹង ៩៧% កំពុងអនុវត្ត និងមិនទាន់អនុវត្ត ១ ស្មើនឹង ៣%។

(រូបភាពទី៣)

*រូបភាពទី៣៖ លទ្ធផលនៃការអនុវត្តសកម្មភាពរង តាមកម្មវិធី (ឧបសម្ព័ន្ធទី៣)*




### ១.៤ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ ទាំង ១៥ចំណុច

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានចូលរួមអនុវត្តកំណែទម្រង់ ១៥ចំណុច ឆ្នាំ ២០១៦-២០១៨ របស់ក្រសួងអប់រំយុវជននិងកីឡាជាលទ្ធផលប្រចាំឆ្នាំមានដូចខាងក្រោម៖

*កំណែទម្រង់ទី ១ ៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:*

- អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា
- អនុវត្តកិច្ចលទ្ធកម្ម តាមរយៈ ក្រុមលទ្ធកម្មនៃអង្គភាពថវិកាមន្ទីរអប់រំ យុវជន និងកីឡាខេត្ត
- ផ្ទេរថវិកាដំណើរការសាលារៀន តាមរយៈគណនីធានាគារអេស៊ីលីដា (ACLEDA)សាខាក្រុង ស្រុក
- បើកផ្តល់ថវិកាបៀវត្សរ៍ប្រចាំខែ ប្រាក់ឧបត្ថម្ភផ្សេងៗ (ប្រាក់ម៉ោងបន្ថែមមធ្យមសិក្សា ប្រាក់បង្រៀនថ្ងៃព្រហស្បតិ៍ ប្រាក់ឧបត្ថម្ភជីវភាពគ្រូនៅតំបន់ជួបការលំបាក ប្រាក់លំហែមាតុភាព ប្រាក់សោធនិវត្តន៍ ប្រាក់អាហារូបករណ៍គរុសិស្ស ប្រាក់បេសកកម្ម ) តាមគណនីធានាគារអេស៊ីលីដា (ACLEDA) សាខាក្រុង ស្រុកជូនបុគ្គលិកអប់រំទូទាំងខេត្ត ។

*កំណែទម្រង់ទី ២ ៖ ការពង្រាយគ្រូបង្រៀន*

- បានផ្សព្វផ្សាយលិខិតលេខ: ១០ អយក.សណន ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ ស្តីពីការសុំផ្លាស់ទីកន្លែងបម្រើការងារ របស់មន្ត្រីរាជការ ក្រសួងអប់រំ យុវជន និងកីឡា ទៅក្រសួង ស្ថាប័នផ្សេង។

*កំណែទម្រង់ទី ៣ ៖ កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន*

- ផ្គត់ផ្គង់សម្ភារបង្រៀន និងរៀន សម្ភារប្រើប្រាស់ការងាររដ្ឋបាល ។
- កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន (ជួសជុលបង្គន់អនាម័យ ៣បន្ទប់ ថែទាំបណ្តាញទឹកភ្លើង រោងម៉ាស៊ីន សម្ភារបច្ចេកទេស ព័ត៌មានវិទ្យា )។

*កំណែទម្រង់ទី ៤ ៖ ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន*

- បានរៀបចំស្នើតម្លើងកាំប្រាក់ជូនបុគ្គលិកអប់រំ សម្រាប់ឆ្នាំ ២០១៨ ចំនួន ៣២៦៧នាក់ ទៅក្រសួងអប់រំយុវជន និងកីឡា ។

*កំណែទម្រង់ទី ៥ ៖ ការងារអធិការកិច្ច*

- បានធ្វើអធិការកិច្ចតាមកាលកំណត់នៅសាលាបឋមសិក្សានិងមធ្យមសិក្សាចំនួន ៦៨ សាលារៀនក្នុងនោះបឋមសិក្សា ៥៤ អនុវិទ្យាល័យ ១០ និងវិទ្យាល័យ ៤ ជាមួយគ្នានេះ បានសហការជាមួយអង្គការSave The Children ចុះអធិការកិច្ចសាលាបឋមសិក្សា ១៥សាលា ។

*កំណែទម្រង់ទី ៧ ៖ កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ*

- បានផ្តល់សិទ្ធអំណាចឲ្យគ្រូតាមមុខវិជ្ជាទទួលខុសត្រូវ រៀបចំការប្រឡងឆមាស នៅមធ្យមសិក្សា ទុតិយភូមិ
- បានគ្រោងមណ្ឌលប្រឡងនៅក្នុងទីរួមខេត្តដើម្បីងាយស្រួលគ្រប់គ្រង
- រៀបចំគំរូវិញ្ញាសាសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ
- បង្កើតក្លឹបសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រនៅតាមសាលាមធ្យមសិក្សា
- ណែនាំការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិលើមុខវិជ្ជាភាសាខ្មែរដែលចែកចេញជាពីរវិញ្ញាសាគឺតែងសេចក្តី និងសរសេរតាមអាន
- បានជួសជុលមណ្ឌលប្រឡងចំនួន១មណ្ឌលនៅវិទ្យាល័យព្រះបាទសុរាម្រឹត២អគារ ១៦បន្ទប់
- 

  បាននផ្តល់សិទ្ធឲ្យអង្គភាពប្រឆាំងអំពើពុករលួយសង្គមស៊ីវិលអ្នកសារព័ត៌មានចូលរួមធ្វើការសង្កេតអំពីដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ប្រកបដោយគោលការណ៍៤យ៉ាង៖ ច្បាប់យុតិធម៌ តម្លាភាព និងលទ្ធផលអាចទទួលយកបាន

- លុបបំបាត់នូវភាពអនាធិបតេយ្យ ការសូកប៉ាន់ដើម្បីជាប់ ក្នុងគោលដៅលើកស្ទួយការគោរពគ្រូបង្រៀននិងស្តារឡើងវិញកិត្តិយសរបស់គ្រូបង្រៀន
- រៀបចំគំរូវិញ្ញាសាសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ
- បង្កើតក្លឹបសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រនៅតាមសាលាមធ្យមសិក្សា
- បង្កើតឲ្យមានការប្រឡងមុខវិជ្ជាភាសាខ្មែរពីរវិញ្ញាសាគឺតែងសេចក្តី និងសរសេរតាមអាន។

*កំណែទម្រង់ទី ៩ ៖ ការសាងសង់អគារសិក្សានិងការជួសជុល*

- បានទទួលគម្រោង និងសាងសង់បង្គន់អនាម័យ និងប្រព័ន្ធទឹកស្អាតចំនួន ៥កន្លែង ផ្តល់ជូនសាលារៀន បឋមសិក្សាដែលគ្មានបង្គន់អនាម័យ និងអនុវត្តនីតិវិធីលទ្ធកម្ម (សាកសួរថ្លៃ) ដោយអង្គភាព សាលារៀនផ្ទាល់
- បានបង្កើត និងអនុវត្តទម្រង់រាយការណ៍ អំពីអគារសិក្សារងផលប៉ះពាល់ខ្យល់កន្ត្រាក់
- បានពិនិត្យផ្ទៀងផ្ទាត់ស្ថិតិអគារសិក្សា ដែលជាអំណោយដ៏ថ្លៃថ្លា និងខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតី តេជោហ៊ុន សែន**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាលទ្ធផល អគារសរុបមាន**១៦៥ខ្នង ១០៨២បន្ទប់**ក្នុងនោះមានអគារសិក្សា ១៣៣ខ្នង ៩៤២បន្ទប់ ទីចាត់ការ ១៧ខ្នង ៥៣បន្ទប់ បណ្ណាល័យ ២ខ្នង ៦បន្ទប់ អគារកាត់ដេរ ៨ខ្នង ២៣បន្ទប់ និងអគារស្នាក់នៅគ្រូ-សិស្ស ៥ខ្នង ៥០បន្ទប់ ។
- បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថានភាពសំណង់អគារសិក្សា រដ្ឋបាល ផ្ទះសំណាក់គ្រូ បង្គន់អនាម័យ ប្រចាំឆ្នាំសិក្សា២០១៦-២០១៧ ។

*កំណែទម្រង់ទី ១១ ៖ ការលើកកម្ពស់វិស័យកីឡា*

- បានលើកគម្រោងនិងជួសជុលទីលានកីឡាអត្តពលកម្ម ១កន្លែង (លោតចម្ងាយ) ប៉េតង់ ១កន្លែង និងបាល់ទាត់ ១កន្លែង រួចរាល់ ។

*កំណែទម្រង់ទី ១២ ៖ ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន*

- យុវជនចំនួន ២១នាក់ បានចូលរួមធ្វើសកម្មភាពស្ម័គ្រចិត្ត នៅមជ្ឈមណ្ឌលយុវជន
- បានបណ្តុះបណ្តាលនវកាយវីទ្ធិសរុបចំនួន ៣៧៥នាក់ ស្រី ១៥៥នាក់

- បានបណ្តុះបណ្តាលយុវជន ស្តីពីសកម្មភាពស្ម័គ្រចិត្តនៅសហគមន៍ មានយុវជនចូលរួម ៦០នាក់
- បានផ្សព្វផ្សាយអប់រំស្តីពីការជ្រើសរើសមុខជំនាញសិក្សា តម្រូវការទីផ្សារការងារ និងបង្កើតមុខរបរ ដល់យុវជនក្រៅសាលាចំនួន ៣០នាក់ ស្រី ២៧នាក់។

*កំណែទម្រង់ទី ១៣ ៖ ការអប់រំបច្ចេកទេស*

- បានផ្សព្វផ្សាយលិខិតពាក់ព័ន្ធនិងការអប់រំបច្ចេកទេស ទៅដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សាទូទាំងខេត្ត
- រៀបចំឱ្យមានកម្មវិធីអនុវត្តជាក់ស្តែង មុខវិជ្ជា កសិកម្ម និងអគ្គីសនី នៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទនរោត្តម សីហមុនី ស្រុកកំពង់ត្រឡាច
- ចុះទស្សនៈកិច្ចសិក្សាផ្ទាល់នៅតាមរោងចក្រសហគ្រាស និងដកបទពិសោធន៍ជាមួយវិទ្យាស្ថាន កំពង់ឈើទាល ខេត្តកំពង់ធំ
- បានកសាងកម្មវិធីសិក្សា និងសៀវភៅសិក្សាជំនាញផ្នែកបច្ចេកទេស កសិកម្ម និងអគ្គិសនី
- បានផ្សព្វផ្សាយលិខិតពាក់ព័ន្ធនិងការអប់រំបច្ចេកទេស ទៅដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សាទូទាំងខេត្ត។

*កំណែទម្រង់ទី ១៤ ៖ ការបង្កើតសាលារៀនជំនាន់ថ្មី*

- បានកំណត់សាលារៀនគោលដៅ ៨សាលារៀនបឋមសិក្សា (១ក្រុង ១ស្រុក ១សាលារៀន)ប៉ុន្តែមិនទាន់បានដំណើរការ។

# ២.លទ្ធផលតាមអនុវិស័យ

## ២.១ អនុវិស័យការអប់រំកុមារតូច

### ក.លទ្ធផលសម្រេចបាន

**ក.១.ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា**

ក.១.១. ការប្រែប្រួលស្ថានភាពអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធអប់រំ

| ល.រ | បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | ឆ្នាំសិក្សា ២០១៧-២០១៨ | កើន-ថយ(+/-) |
|---|---|---|---|---|
| ១ | ចំនួនអគារសិក្សា | 16 | 27 | +11 |
| | មត្តេយ្យដាច់ពីបឋម | 18 | 18 | ដ |
| | ចំនួនថ្នាក់ | 61 | 63 | +2 |
| ២ | មត្តេយ្យក្នុងបឋមសិក្សា | 87 | 92 | +5 |
| | ចំនួនថ្នាក់ | 142 | 149 | +7 |
| ៣ | មត្តេយ្យសិក្សាសហគមន៍ | 134 | 159 | +25 |
| | ចំនួនថ្នាក់ | 134 | 163 | +29 |
| ៤ | មត្តេយ្យសិក្សាឯកជន | 5 | 9 | +4 |
| | ចំនួនថ្នាក់ | 29 | 49 | +20 |
| ៥ | អប់រំកុមារតូចតាមផ្ទះ | | | |
| | ឃុំ | 60 | 61 | +1 |
| | ភូមិ | 209 | 219 | +10 |
| | ក្រុម | 1019 | 1017 | -2 |

*ប្រភពទិន្នន័យ៖ ការិយាល័យអប់រំកុមារតូច*

ក.១.២. ការប្រែប្រួលស្ថានភាពផ្គត់ផ្គង់បុគ្គលិកអប់រំ

| ល.រ | បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | | ឆ្នាំសិក្សា ២០១៧-២០១៨ | | កើន-ថយ(+/-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | មត្តេយ្យសិក្សារដ្ឋ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | បុគ្គលិកបង្រៀន | 203 | 197 | 212 | 206 | +9 | +9 |
| | បុគ្គលិកមិនបង្រៀន | 13 | 13 | 14 | 14 | ដ | ដ |
| ២ | មត្តេយ្យសិក្សាឯកជន | 36 | 33 | 78 | 68 | +42 | +35 |
| ៣ | មត្តេយ្យសិក្សាសហគមន៍ | 134 | 126 | 163 | 154 | +29 | +28 |
| ៤ | ចំនួនម៉ែៗកុមារតាមផ្ទះ | 6099 | 6099 | 7023 | 7023 | +924 | +924 |

*ប្រភពទិន្នន័យ៖ ការិយាល័យអប់រំកុមារតូច*

### ក.១.៣. ការប្រែប្រួលស្ថានភាពចូលរៀនរបស់សិស្ស

| ល.រ | បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | | ឆ្នាំសិក្សា ២០១៧-២០១៨ | | កើន-ថយ(+/-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | មត្តេយ្យសិក្សារដ្ឋ | **6160** | **3069** | **6536** | **3273** | **+376** | **+204** |
| | ក្នុងបឋមសិក្សា | 4063 | 2070 | 4326 | 2197 | +263 | +127 |
| | ដាច់ពីបឋមសិក្សា | 2097 | 999 | 2210 | 1076 | +113 | +77 |
| ២ | មត្តេយ្យសិក្សាឯកជន | 764 | 378 | 1343 | 683 | +579 | +305 |
| ៣ | មត្តេយ្យសិក្សាសហគមន៍ | 3466 | 1710 | 4235 | 2190 | +769 | +480 |
| ៤ | ចំនួនកុមារតូចតាមផ្ទះ | 7017 | 3560 | 7436 | 3709 | +419 | +149 |

*ប្រភពទិន្នន័យ៖ ការិយាល័យអប់រំកុមារតូច*

ក្នុងឆ្នាំសិក្សា២០១៧-២០១៨នេះសាលាមត្តេយ្យសិក្សាដាច់ពីបឋមមានការកើនឡើងចំនួន២ថ្នាក់ សាលាមត្តេយ្យសិក្សាក្នុងបឋមមានការកើនឡើងចំនួន៥សាលា មានថ្នាក់ចំនួន១៧ថ្នាក់ ដោយសារការពង្រីកថ្នាក់មត្តេយ្យសិក្សាដាច់ពីបឋម និងមត្តេយ្យក្នុងបឋមសិក្សាជាមួយគ្នានេះដែរមត្តេយ្យសិក្សាសហគមន៍ក៏មានការកើនឡើងចំនួន២៥កន្លែង ស្មើនឹង២៥ថ្នាក់បន្ថែមទៀតនៅតំបន់ជួបការលំបាក ជាពិសេសតំបន់លិចទឹក និងបណ្តែតទឹក ដោយការសហការគាំទ្រពីអង្គការដៃគូរអភិវឌ្ឍន៍ SC និងWVI-Cក្រុមប្រឹក្សាឃុំ និងសហគមន៍មានការយល់ដឹងកាន់តែប្រសើរអំពីសារៈសំខាន់នៃការអប់រំកុមារតូចដែលនិន្នាការនេះបានធ្វើឲ្យមានការកើនឡើងចំនួនសិស្សមត្តេយ្យសិក្សាផងដែរ។

### ក.១.៤.ការប្រែប្រួលគុណភាពនៃសេវាអប់រំ៖ ផ្តោតលើគុណភាពទាំង៥ ភាគរយកុមារអាយុពី៣ឆ្នាំក្នុងកម្មវិធីអប់រំកុមារតូចគ្រប់រូបភាព

| ល.រ | បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | | ឆ្នាំសិក្សា ២០១៧-២០១៨ | | កើន-ថយ(+/-) | |
|---|---|---|---|---|---|---|---|
| | | %សរុប | %ស្រី | %សរុប | %ស្រី | %សរុប | %ស្រី |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | មត្តេយ្យសិក្សារដ្ឋ | 4.25 | 4.23 | 4.66 | 4.95 | +0.41 | +0.72 |
| ២ | មត្តេយ្យសិក្សាឯកជន | 1.42 | 1.57 | 3.30 | 3.74 | +1.88 | +2.17 |
| ៣ | មត្តេយ្យសិក្សាសហគមន៍ | 3.55 | 3.48 | 4.60 | 5.25 | +1.05 | +1.77 |
| ៤ | អប់រំកុមារតូចតាមផ្ទះ | 10.55 | 11.06 | 9.88 | 9.88 | -0.84 | -1.18 |
| សរុប | | **19.77** | **20.34** | **22.28** | **23.82** | **+2.50** | **+3.48** |

*ប្រភពទិន្នន័យ៖ ការិយាល័យអប់រំកុមារតូច*

ភាគរយកុមារអាយុពី៤ឆ្នាំក្នុងកម្មវិធីអប់រំកុមារតូចគ្រប់រូបភាព

| ល.រ | បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | | ឆ្នាំសិក្សា ២០១៧-២០១៨ | | កើន-ថយ(+/-) | |
|---|---|---|---|---|---|---|---|
| | | %សរុប | %ស្រី | %សរុប | %ស្រី | %សរុប | %ស្រី |
| ១ | មត្តេយ្យសិក្សារដ្ឋ | 15.28 | 15.53 | 16.75 | 17.50 | +1.47 | +1.97 |
| ២ | មត្តេយ្យសិក្សាឯកជន | 1.99 | 1.95 | 3.20 | 3.37 | +1.21 | +1.42 |
| ៣ | មត្តេយ្យសិក្សាសហគមន៍ | 8.17 | 8.28 | 11.32 | 12.43 | +3.15 | +4.15 |
| ៤ | អប់រំកុមារតូចតាមផ្ទះ | 11.97 | 12.31 | 11.78 | 12.13 | -0.19 | -0.18 |
| សរុប | | **37.41** | **38.07** | **43.05** | **45.43** | **+5.64** | **+7.36** |

*ប្រភពទិន្នន័យ៖ ការិយាល័យអប់រំកុមារតូច*

ភាគរយកុមារអាយុ៥ឆ្នាំ ក្នុងកម្មវិធីអប់រំកុមារតូចគ្រប់រូបភាព

| ល.រ | បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | | ឆ្នាំសិក្សា ២០១៧-២០១៨ | | កើន-ថយ(+/-) | |
|---|---|---|---|---|---|---|---|
| | | %សរុប | %ស្រី | %សរុប | %ស្រី | %សរុប | %ស្រី |
| ១ | មត្តេយ្យសិក្សារដ្ឋ | 34.00 | 34.60 | 34.62 | 34.87 | +0.62 | +0.27 |
| ២ | មត្តេយ្យសិក្សាឯកជន | 3.15 | 3.09 | 4.86 | 4.62 | +1.71 | +1.53 |
| ៣ | មត្តេយ្យសិក្សាសហគមន៍ | 18.32 | 18.47 | 20.25 | 20.50 | +1.93 | +2.03 |
| ៤ | អប់រំកុមារតូចតាមផ្ទះ | 8.17 | 8.51 | 8.89 | 9.30 | +0.72 | +0.79 |
| សរុប | | **63.64** | **64.67** | 68.62 | 69.29 | +4.98 | +4.62 |

*ប្រភពទិន្នន័យ៖ ការិយាល័យអប់រំកុមារតូច*

ការចូលរៀនរបស់កុមារអាយុ៥ឆ្នាំក្នុងឆ្នាំសិក្សា២០១៧-២០១៨ មានការកើនឡើងគួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំសិក្សា២០១៦-២០១៧ និន្នាការនេះដោយសារ មន្ទីរបានសហការជាមួយអង្គការសង្គ្រោះកុមារ (SC) អនុវត្តគម្រោងអប់រំកុមារតូចនៅតំបន់លិចទឹក និងបណ្តែតទឹកនៅក្រុងកំពង់ឆ្នាំង បរិបូណ៌ កំពង់លែង កំពង់ត្រឡាច ជលគិរី និងរលាប្អៀរ។

រូបភាពទី៤ ៖ លទ្ធផលធៀបនិងចំណុចដៅ បច្ចុប្បន្នភាពESPឆ្នាំ ២០១៥-២០១៧




*ប្រភពទិន្នន័យ៖ការិយាល័យអប់រំកុមារតូច(មូលដ្ឋានគិតយកស្ថិតិកុមារអាយុ៥ឆ្នាំចំណោលប្រជាជនក្រសួងផែនការ)*

ភាគរយកុមារអាយុ៣ឆ្នាំ និង៤ឆ្នាំ ក្នុងកម្មវិធីអប់រំកុមារតូចគ្រប់រូបភាពឆ្នាំសិក្សា២០១៧-២០១៨ សម្រេចបានលើសចំណុចដៅក្នុងបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៥-២០១៧ ដោយឡែក ភាគរយកុមារអាយុ ៥ឆ្នាំ នៅមានគំលាតពីចំណុចដៅប្រមាណ ២.៣% មិនសម្រេចចំណុចដៅនៅឡើយ។

រូបភាពទី៥ ៖ ភាគរយកុមារអាយុ៥ឆ្នាំក្នុងកម្មវិធីអប់រំកុមារតូចគ្រប់រូបភាពនៅតាមក្រុងស្រុកឆ្នាំសិក្សា២០១៧-២០១៨



*ប្រភពទិន្នន័យៈ ការិយាល័យអប់រំកុមារតូច*

ក្នុងឆ្នាំសិក្សា២០១៧-២០១៨នេះការចូលរៀនរបស់កុមារអាយុ៥ឆ្នាំ ក្នុងកម្មវិធីអប់រំកុមារតូចគ្រប់រូបភាព នៅក្រុង ស្រុកចំនួន ៥ មានការកើនឡើងគួរឱ្យកត់សម្គាល់ និងសម្រេចចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្រ្តវិស័យអប់រំ ឆ្នាំ២០១៥-២០១៧ មួយវិញទៀត ស្រុកចំនួន២ មានការកើនឡើងតិចតួច ដោយឡែក ស្រុកបរិបូណ៌ មានការថយចុះប្រមាណ ៥% ។

### ក.១.៤.១. ការរៀបចំបរិស្ថានសិក្សា និងសម្ភារសិក្សា

- សាលាមត្តេយ្យធនធាន០៣កន្លែងសាលាមត្តយ្យជាច់ចំនួន០៨កន្លែងមត្តេយ្យសហគមន៍ចំនួន១១កន្លែងមានការរៀបចំបរិស្ថានក្រៅនិងក្នុងថ្នាក់បានល្អ
- រៀបចំបរិស្ថានផ្ទះឪពុកម្តាយគំរូរបស់កម្មវិធីអប់រំកុមារតូចតាមផ្ទះបានចំនួន៨១ភូមិ ឧបត្ថម្ភដោយអង្គការ SC
- សាលាមត្តេយ្យរដ្ឋ១០៥សាលាបានទទួលថវិកាកម្មវិធីនិងជំនួយដើម្បីកែលម្អសាលារៀនដើម្បីផលិតសម្ភារឧបទ្ទេសរៀបចំរដ្ឋបាលថ្នាក់និងបរិស្ថាន
- សាលាមត្តេយ្យធនធានចំនួន៦កន្លែងបានទទួលសង្ហារឹមនិងសម្ភារៈបរិក្ខាបំពាក់តាមស្តង់ដាមត្តេយ្យធនធានបានគ្រប់ចំនួន
- ផ្តល់សម្ភារ អនាម័យនិងសម្ភារសិក្សាដល់មត្តេយ្យសិក្សាសហគមន៍ចំនួន៧០កន្លែងដែលមាន៧០កញ្ចប់និងផ្តល់សម្ភារដល់កម្មវិធីអប់រំកុមារតូចតាមផ្ទះចំនួន២៣កន្លែងដែលមាន២៣កញ្ចប់
- ផ្តល់ឯកសារគោលផ្នែកមត្តេយ្យសិក្សាចំនួន១២៣៨ក្បាលដល់ស្រុកទាំង៨
- ផ្តល់កុំព្យូទ័រចំនួន០៨គ្រឿងដល់ជំនាញអប់រំ ការិយាល័យស្រុកទាំង០៨ដែលជាគម្រោងគាំទ្រវិស័យអប់រំទី២ (SESSP-GPE) និងផ្តល់កុំព្យូទ័រលើតុ ១គ្រឿង ដល់សាលាមត្តេយ្យសិក្សាមិត្តភាព ក្រុងកំពង់ឆ្នាំង (ថវិការដ្ឋឆ្នាំ២០១៧)
- បានលាប ថ្នាំផ្តល់សម្ភារសិក្សានិងសម្លៀកបំពាក់ដល់កុមារនៅសាលាមត្តេយ្យសហគមន៍ចំ

នូន០២សាលាក្នុងស្រុកទឹកផុសដែលជាអំណោយរបស់សប្បុរសជន ក្រុមមិត្តរួមជំនាន់ វិ.សុរាម្រឹត៩៥-៩៦

- ផ្តល់សម្ភារសិក្សាថ្នាក់មត្តេយ្យសិក្សាសហគមន៍ ចំនួន៤៣កន្លែង ឧបត្ថម្ភដោយអង្គការ CYK
- ផ្តល់សម្ភារសិក្សាសម្រាប់ជ័យលាភីពីលេខ១ដល់លេខ៣ដល់សាលាមត្តេយ្យសិក្សារដ្ឋ៣កន្លែងនិងសាលាមត្តេយ្យសិក្សាសហគមន៍បាន៣កន្លែងផ្តល់សម្ភារដល់ថ្នាក់មត្តេយ្យសិក្សាសហគមន៍បាន១០កន្លែងក្នុងស្រុករលាប្អៀរនិងស្រុកបរិបូណ៌ ឧបត្ថម្ភដោយអង្គការ WVI-C
- ផ្តល់សម្ភារសិក្សានិងសម្ភារល្បែងដល់មត្តេយ្យសិក្សាសហគមន៍និងអប់រំតាមផ្ទះបានចំនួន២២ឃុំក្នុងស្រុកជលគីរីកំពង់លែងបរិបូណ៌និងរលាប្អៀរឧបត្ថម្ភដោយ អង្គការSC
- ផ្តល់សម្ភារបើកថ្នាក់មត្តេយ្យសិក្សារដ្ឋបាន២កន្លែងនៅស្រុកទឹកផុសនិងស្រុករលាប្អៀរឧបត្ថម្ភដោយអង្គការCYK។

### ក.១.៤.២.ការរៀបចំកម្មវិធីសិក្សា និងឯកសារ

- សាលាមត្តេយ្យសិក្សារដ្ឋនិងសហគមន៍បានអនុវត្តតាមកម្មវិធីសិក្សាកុមារអាយុ ៣ឆ្នាំ ៤ឆ្នាំ ៥ឆ្នាំ ស្របតាមសៀវភៅសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡាសម្រេចបាន ៨៥% ដោយផ្អែកស្តង់ដារអប្បរមារបស់សាលា និងថ្នាក់មត្តេយ្យសិក្សារដ្ឋ និងស្តង់ដារអប្បបរមាថ្នាក់មត្តេយ្យសិក្សាសហគមន៍
- កម្មវិធីអប់រំកុមារតូចតាមផ្ទះបានអនុវត្តមេរៀនសម្រាប់ការប្រជុំក្រុមឪពុកម្តាយប្រចាំខែទៅតាមកឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡាបាន២០%និងឯកសាររបស់អង្គការ Save the children បានចំនួន៧០% នៅតាមតំបន់ជួបការលំបាកគម្រោង បណ្តែតទឹក និងលិចទឹកក្នុងក្រុង-ស្រុកទាំង៦
- ការិយាល័យអប់រំកុមារតូចមន្ទីរ-ស្រុកបានរៀបចំឯកសារ-មេរៀននិងកម្មវិធីសម្រាប់វគ្គបណ្តុះបណ្តាលបំប៉នដំបូងដល់គ្រូមត្តេយ្យសិក្សាសហគមន៍ជា៧ដំណាក់កាលដែលមានរយៈពេល០៥ថ្ងៃក្នុងដំណាក់កាលនិមួយៗ ព្រមទាំងបានចូលរួមរៀបចំឯកសារមេរៀនសម្រាប់បំប៉នគ្រូបង្គោលនិងឪពុកម្តាយបង្គោលកម្មវិធីអប់រំកុមារតូចតាមផ្ទះថ្នាក់តំបន់និងសម្រាប់គម្រោងអប់រំកុមារតូចតំបន់បណ្តែតទឹកនិងលិចទឹកគាំទ្រដោយអង្គការ Save the

Childrenនិងជាពិសេសថ្មីមួយទៀតការិយាល័យអប់រំកុមារតូចមន្ទីរនិងមន្ត្រីជំនាញតាមក្រុង-ស្រុកនាយិកានិងគ្រូមត្តេយ្យសិក្សាធនធានបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋរយៈពេល០៣ថ្ងៃនៅខេត្តកំពង់ធំរៀបចំដោយនាយកដ្ឋានអប់រំកុមារតូចសហការជាមួយនាយកដ្ឋានបណ្តុះបណ្តាលសំដៅធ្វើយ៉ាងណាអោយកម្មវិធីសិក្សាមត្តេយ្យសិក្សារដ្ឋស្របតាមស្តង់ដារអាស៊ាន។

### ក.១.៤.៣.ការទទួលបានចំណេះដឹង និងសមត្ថភាពរបស់កុមារ និងគ្រូបង្រៀន

- កុមារដែលបានទទួល សេវាអប់រំគ្រប់រូបភាព មានការអភិវឌ្ឍលើផ្នែកទាំង៥ បានពេញលេញនិងគ្រប់ជ្រុងជ្រោយពិសេសកុមារអាយុ៥ឆ្នាំដោយបាន អនុវត្តតេស្តទៀងទាត់បាន៩៦% ដើម្បីវាស់សមត្ថភាពកុមារ និងបានបញ្ជូនឡើងថ្នាក់ទី១ ១០០%
- គ្រូបង្រៀននៅមត្តេយ្យសិក្សារដ្ឋ និងសហគមន៍មានសមត្ថភាពក្នុងការដឹកនាំសកម្មភាពបង្រៀន ការធ្វើតេស្តកុមារ ការផលិតសម្ភារបង្រៀន ការកែលម្អ បរិស្ថានថ្នាក់រៀន និងបានបង្កើនសមត្ថភាពបន្ថែមជាបន្តៗតាមរយៈ: ការស្រាវជ្រាវការប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ វគ្គបំប៉នសមត្ថភាព និងការចុះជួយរបស់ថ្នាក់មន្ទីរ និងក្រុង-ស្រុក។

## ក.២. ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

### ក.២.១ ការអភិវឌ្ឍសមត្ថភាព

- បំប៉ន សមត្ថភាពដល់មាតាបិតា កុមារ៣ឆ្នាំ ទៅក្រោម៦ឆ្នាំ រៀននៅសាលាមត្តេយ្យសហគមន៍បានចំនួន ៤៧នាក់ និងវគ្គបំប៉នស្តីពីបច្ចេកទេស ដល់គ្រូមត្តេយ្យសិក្សា សហគមន៍ចំនួន ២វគ្គ អ្នកចូលរួមសរុប ៣៧នាក់ ឧបត្ថម្ភ ដោយ អង្គការ WVI-C ស្រុកបរិបូណ៌
- ប្រជុំក្រុមការងារ បច្ចេកទេសការងារអប់រំ កុមារតូច នៅខេត្តក្រចេះ មន្ទីរ និងស្រុកចូលរួម ចំនួន ១១នាក់ និងពោធិ៍សាត់ ចំនួន ១៩នាក់
- បំប៉ន ដំបូងស្តីពីបច្ចេកទេសគ្រូមត្តេយ្យសិក្សាសហគមន៍ តំបន់បណ្តែត ទឹក និងលិចទឹក បានចំនួន ៣វគ្គ អ្នកចូលរួម៣៥នាក់ ឧបត្ថម្ភដោយអង្គការ SC
- ប្រជុំពង្រឹងបណ្តាញអប់រំកុមារតូចថ្នាក់ស្រុកបានចំនួន៥លើកនិងបណ្តាញឃុំ បានចំនួន១៥លើក

- បណ្តុះបណ្តាលដល់គ្រូបង្គោល និងគកនកស្តីពីការងារបច្ចេកទេស រយៈពេល ០៥ថ្ងៃបានចំនួន៨វគ្គ អ្នកចូលរួមសរុប ១៣២នាក់
- បំប៉នរំលឹកដល់គ្រូបង្គោល គកនក និងម៉ែបង្គោល រយៈពេល ០៣ថ្ងៃ បានចំនួន០៨វគ្គ អ្នកចូលរួមសរុប ១៣២នាក់ឧបត្ថម្ភដោយអង្គការ SC។

**ក.២.២ការពិនិត្យតាមដាន**

- បានពិនិត្យតាមដានលើការងាររដ្ឋបាលការរៀបចំបរិស្ថានថ្នាក់និងការងារបច្ចេកទេសបង្រៀននិងរៀននៅសាលាមត្តេយ្យសិក្សារដ្ឋបានចំនួន៥៨សាលានិងមត្តេយ្យសហគមន៍បានចំនួន២០ថ្នាក់
- បានពិនិត្យតាមដានលើការប្រជុំប្រចាំខែរបស់ក្រុមម៉ែ នៃកម្មវិធីអប់រំកុមារតូចតាមផ្ទះ នៅតំបន់លិចទឹក និងបណ្តែតទឹកចំនួន ៨១ភូមិ
- បានពិនិត្យតាមដាន និងវាយតម្លៃសាលាមត្តេយ្យសិក្សារដ្ឋ និងសហគមន៍ល្អ បានចំនួន ២៨សាលា ឧបត្ថម្ភដោយអង្គការ WVI-C
- ចុះប្រមូលទិន្និន័យ-ស្ថិតិការងារអប់រំកុមារតូចបាន៨ស្រុក។

## ខ.វឌ្ឍនភាពនៃការសម្រេចបានសូចនាករអនុវិស័យអប់រំកុមារតូច




គោលនយោបាយទី១ មានសូចនាករសរុប ៧ ក្នុងនោះសម្រេចចំណុចដៅឆ្នាំសិក្សា២០១៧-២០១៨(បច្ចុប្បន្នភាពESP 2015-2017) មានសូចនាករ៣ ស្មើនឹង៤៣ % គឺភាគរយកុមារអាយុ ៣ឆ្នាំ ៤ឆ្នាំបានចូលរៀន និងភាគរយសេវាអប់រំកុមារតូចអនុវត្តតេស្តទៀងទាត់វាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ សូចនាករ ១ ស្មើនឹង ១៤% លទ្ធផលអាចទទួលយកបាន និង សូចនាករ៣ ស្មើនឹង ៤៣% មិនសម្រេចចំណុចដៅ។ (ឧបសម្ព័ន្ធទី៤)

**គ.បញ្ហាប្រឈម**

- o កង្វះថវិកាក្នុងការកសាងសកម្មភាពផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការចុះពិនិត្យតាមដានថ្នាក់ខេត្ត ថ្នាក់ស្រុក

ការបំប៉នសមត្ថភាពនិងបណ្តុះបណ្តាលដល់គ្រូបឋមសិក្សាដែលបង្រៀនថ្នាក់មត្តេយ្យសិក្សារដ្ឋនិងគ្រូមត្តេយ្យសិក្សាសហគមន៍ចាស់ និងថ្មី

- o គ្រូបង្គោល និងគកនក នៅតំបន់បណ្តោតទឹក និងលិចទឹក មិនទាន់មានសមត្ថភាព គ្រប់គ្រាន់ក្នុងការដឹកនាំការប្រជុំក្រុមឪពុកម្តាយប្រចាំខែ
- o សមត្ថភាពមន្ត្រីជំនាញក្នុងការប្រើប្រាស់កុំព្យូទ័រនៅមានកម្រិត។

ជារួមក្នុងឆ្នាំសិក្សា២០១៧-២០១៨នេះ ការចូលរៀនរបស់កុមារអាយុ៥ឆ្នាំ មានការកើនឡើងគួរឱ្យកត់សម្គាល់ ជាមួយគ្នានេះដែរការចូលរៀនរបស់កុមារអាយុ ៣ឆ្នាំ និង៤ឆ្នាំ មានការកើនឡើងរហូតសម្រេចចំណុចដៅប្រចាំឆ្នាំសិក្សា២០១៧-២០១៨ នៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៥-២០១៧ ប៉ុន្តែការចូលរៀនរបស់កុមារអាយុ៣ឆ្នាំ បើធៀបនឹងចំនួនកុមារអាយុ៣ឆ្នាំសរុបទូទាំងខេត្តសម្រេចបាននៅមានកម្រិតទាបនៅឡើយ ជាមួយគ្នានេះ សេវាអប់រំកុមារតូចគោរពតាមស្តង់ដាគុណភាព មិនទាន់បានអនុវត្តនៅឡើយ ដែលត្រូវបន្តផ្តោតការយកចិត្តទុកអនុវត្ត តាមរយៈការបង្កើនកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ ជាពិសេសដៃគូអភិវឌ្ឍវិស័យអប់រំ ។

## ២.២ អនុវិស័យការអប់រំបឋមសិក្សា

## ក.លទ្ធផលសម្រេចបាន

### ក.១.ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ក.១.១. ការប្រែប្រួលហេដ្ឋារចនាសម្ព័ន្ធអប់រំ ស្ថានភាពបុគ្គលិកអប់រំ និងសិស្ស (រដ្ឋ)

| ល.រ | បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | ឆ្នាំសិក្សា ២០១៧-២០១៨ | កើន-ថយ (+/-) |
|---|---|---|---|---|
| ១ | ចំនួនសាលារៀន | 273 | 275 | +2 |
| ២ | ចំនួនកម្រងសាលារៀន | 48 | 48 | -៉- |
| ៣ | ចំនួនសាលារៀនមិនគ្រប់កម្រិត | 6 | 6 | -៉- |
| ៤ | % សាលាកុមារមេត្រីកម្រិតមធ្យម | 36.26% | 40.30% | +4.04% |
| ៥ | % សាលាកុមារមេត្រីកម្រិតអភិវឌ្ឍ | 57.14% | 52.01% | -5.13% |
| ៦ | ចំនួនថ្នាក់រៀន | 2,211 | 2,217 | +6 |
| ៧ | ចំនួនបន្ទប់រៀន | 1,488 | 1495 | +7 |
| ៨ | ចំនួនសិស្សសរុប | 74,059 | 74,114 | +55 |
| ៩ | ចំនួនសិស្សស្រី | 36,228 | 36,176 | -52 |
| ១០ | ចំនួនសិស្សក្រីក្រ | 10,032 | 9,987 | -45 |
| ១១ | ចំនួនបុគ្គលិកសរុប | 2,195 | 2,153 | -42 |
| ១២ | ចំនួនបុគ្គលិកស្រី | 976 | 993 | +17 |
| ១៣ | ចំនួនបុគ្គលិកបង្រៀនសរុប | 1802 | 1675 | -127 |
| ១៤ | ចំនួនបុគ្គលិកបង្រៀនស្រី | 881 | 809 | -72 |

*ប្រភពទិន្នន័យ៖ការិយាល័យ បឋមសិក្សា*

សាលារៀនបឋមសិក្សាមានការកើនឡើង ២កន្លែង ក្នុងឆ្នាំសិក្សា២០១៧-២០១៨ នៅឃុំក្រាំង្វា ស្រុកសាមគ្គីមានជ័យស្ថិតក្នុងតំបន់ជួបការលំបាក ដោយឡែកសាលារៀនមិនគ្រប់កម្រិតមាន ៦កន្លែង មិនមានការប្រែប្រួលទេ ទន្ទឹមនឹងនេះ ចំនួនសិស្សរៀននៅបឋមសិក្សាមានការកើនឡើងតិចតួចប៉ុណ្ណោះក្នុងឆ្នាំសិក្សា២០១៧-២០១៨នេះ ។

ភាគរយសាលាកុមារមេត្រីកម្រិតអភិវឌ្ឍ ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានការថយចុះប្រមាណ ៥% ដោយសារអនុវត្តឧបករណ៍ស្វ័យវាយតម្លៃសាលារៀន ថ្នាក់រៀន មានភាពសុក្រិតជាងមុន ទិន្នាការនេះបានធ្វើឱ្យភាគរយសាលាកុមារមេត្រីកម្រិតមធ្យម មានការមានការកើនឡើង ។

### ក.១.២.ការសម្រេចបានសូចនាករលទ្ធភាពចូលរៀនសំខាន់ៗ (រដ្ឋ និងឯកជន)

| បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | | ឆ្នាំសិក្សា ២០១៧-២០១៨ | | កើន-ថយ (+/-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អត្រាពិតចូលរៀនថ្មី | 95.75 | 95.51 | 93.96 | 93.79 | -1.79 | -1.72 |
| អត្រារួមចូលរៀនថ្មី | 109 | 107 | 106.30 | 104.59 | -2.70 | -2.04 |
| អត្រាពិតនៃការសិក្សា | 95.52 | 96.43 | 94.33 | 95.17 | -1.19 | -2.26 |
| អត្រារួមនៃការសិក្សា | 106.57 | 106.42 | 105.86 | 105.56 | -0.71 | -1.86 |
| អត្រាបញ្ចប់ការសិក្សា | 82.62 | 85.39 | 82.03 | 86.32 | -0.59 | +0.93 |

*ប្រភពទិន្នន័យ៖ការិ.ផែនការនិងគ្រប់គ្រងជំនួយ*

ការចូលរៀនរបស់កុមារអាយុ៦ឆ្នាំក្នុងឆ្នាំសិក្សា២០១៧-២០១៨ មានការថយចុះប្រមាណជិត២%និន្នាការនេះពាក់ព័ន្ធនឹងកត្តាមួយចំនួនការគ្រប់គ្រងស្ថិតិទិន្នន័យសិស្សចូលរៀនតាមក្រុងស្រុកមួយចំនួន ឪពុកម្តាយសិស្សមួយចំនួនមិនបញ្ជូនកូនគ្រប់អាយុឲ្យចុះឈ្មោះចូលរៀនព្រោះយល់ថាកូននៅតូច គ្រួសារមួយចំនួនទៀតចល័តទីលំនៅទៅតាមមុខរបរ។ ការចូលរៀនរបស់កុមារលើសអាយុនៅថ្នាក់ទី១ ឬនិងកម្រិតបឋមសិក្សា មានលក្ខណ:កាន់តែប្រសើរជាងឆ្នាំសិក្សាមុន ។ ដោយឡែកការរក្សាសិស្សនៅកម្រិតបឋមសិក្សា និងការបញ្ចប់ការសិក្សាមានការថយចុះគួរឱ្យកត់សម្គាល់ និន្នាការនេះពាក់ព័ន្ធនឹងកត្តាមួយចំនួនសិស្សបោះបង់ការសិក្សាទៅរកការងារធ្វើនៅតាមរោងចក្រ។

រូបភាពទី៦៖អត្រាពិតចូលរៀនថ្មី (រដ្ឋនិងឯកជន) តាមក្រុង ស្រុក ឆ្នាំសិក្សា២០១៧-២០១៨



*ប្រភពទិន្នន័យ: ផែនការ និងគ្រប់គ្រងជំនួយ*

ការចូលរៀនរបស់កុមារអាយុ៦ឆ្នាំ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ មានការថយចុះស្ទើរតែគ្រប់ក្រុង ស្រុក បើធៀបនឹងឆ្នាំសិក្សា២០១៦-២០១៧ ជាមួយគ្នានេះលទ្ធផលដែលសម្រេចបានតាមក្រុង ស្រុក មិនសម្រេចចំណុចដៅឆ្នាំសិក្សា២០១៧-២០១៨ នៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៥-២០១៧។

ដោយឡែកស្រុកជលគិរី ស្រុកកំពង់លែង ស្រុកកំពង់ត្រឡាចអត្រាពិតចូលរៀនថ្មីលើស១០០%ប្រការនេះបណ្តាលមកពីការគណនាក្រុមអាយុកុមារ៧០ខែ និងមូលដ្ឋានគិតយកស្ថិតិប្រជាជនតាមចំណោលប្រជាជនរបស់ក្រសួងផែនការ ។

*រូបភាពទី៧៖ អត្រាពិតនៃការសិក្សា(រដ្ឋនិងឯកជន)តាមក្រុង ស្រុក ឆ្នាំសិក្សា២០១៧-២០១៨*




*ប្រភពទិន្នន័យ: ការិយាល័យផែនការ និងគ្រប់គ្រងជំនួយ*

ការចូលរៀនរបស់កុមារអាយុ៦-១១ឆ្នាំ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ នៅក្រុងកំពង់ឆ្នាំង មានការកើនឡើង បើធៀបនឹងឆ្នាំសិក្សា២០១៦-២០១៧ ដោយឡែកស្ទើរតែគ្រប់ស្រុកមានការថយចុះ ជាលទ្ធផល មានស្រុកចំនួន ៣ គឺកំពង់លែង កំពង់ត្រឡាច និងសាមគ្គីមានជ័យ សម្រេចចំណុចដៅឆ្នាំសិក្សា២០១៧-២០១៨ នៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៥-២០១៧ ។

### ក.១.៣. ការប្រែប្រួលលើផ្នែកប្រសិទ្ធភាពនៃសេវាអប់រំ (រដ្ឋ និងឯកជន)

| បរិយាយ | ឆ្នាំសិក្សា ២០១៥-២០១៦ | | ឆ្នាំសិក្សា ២០១៦-២០១៧ | | កើន-ថយ (+/-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អត្រាឡើងថ្នាក់ | 91.25 | 93.72 | 90.20 | 92.20 | -1,05 | -1,52 |
| អត្រាត្រួតថ្នាក់ | 6.36 | 4.74 | 5.99 | 4.37 | -0,37 | -0,37 |
| អត្រាបោះបង់ការសិក្សា | 2.36 | 1.54 | 3.81 | 3.43 | +1.45 | +1.89 |

*ប្រភពទិន្នន័យៈការិយាល័យ ផែនការ និងគ្រប់គ្រងជំនួយ*

អត្រាឡើងថ្នាក់ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានការថយចុះប្រមាណ ជាង១% មួយវិញទៀត អត្រាបោះបង់ ការសិក្សាមានការកើនឡើងប្រមាណជាង ១% ក្នុងនោះការបោះបង់ការសិក្សារបស់សិស្សស្រី មានការកើនឡើងប្រមាណជិត ២% និន្នាការនេះពាក់ព័ន្ធនិងកត្តាមួយចំនួនដូចជាការចំណាក់ស្រុករបស់ឪពុកម្តាយដើម្បីរកការងារធ្វើ និងជីវភាពក្រីក្ររបស់គ្រួសារសិស្ស ។

*របភាពទី៨ៈ អត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សាឆ្នាំសិក្សា២០១៦-២០១៧ តាមក្រុងស្រុក*




*ប្រភពទិន្នន័យ: ការិយាល័យផែនការ និងគ្រប់គ្រងជំនួយ*

មានក្រុងកំពង់ឆ្នាំង ស្រុកទឹកផុស រលាប្អៀរ និងសាមគ្គីមានជ័យ សម្រេចបានអត្រាត្រួតថ្នាក់ទាបជាងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៥-២០១៧ និងស្រុកបរិបូណ៌ កំពង់លែង និងកំពង់ត្រឡាច សម្រេចបានអត្រាត្រួតថ្នាក់ក្នុងរង្វង់៧% ដោយឡែកស្រុកជលគិរី មានអត្រាត្រួតថ្នាក់លើសពី១០% ដែលត្រូវយកចិត្តទុកដាក់កែលម្អលទ្ធផលសិក្សារបស់សិស្ស តាមរយៈការពង្រឹងគុណភាពការប្រជុំក្រុមបច្ចេកទេស

ការធ្វើថ្នាក់និទស្សន៍ដោយគ្រូបង្រៀនល្អជ័យលាភីថ្នាក់ជាតិ
ការធ្វើអធិការកិច្ចជួយគ្រូបង្រៀន ជំរុញការផលិត និងប្រើប្រាស់សម្ភារបង្រៀន និងរៀន ។

រូបភាពទី៩៖ អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សា ទៅមធ្យមសិក្សាបឋមភូមិឆ្នាំសិក្សា ២០១៦-២០១៧ (រដ្ឋនិងឯកជន)




*ប្រភពទិន្នន័យ: ការិយាល័យផែនការ និងគ្រប់គ្រងជំនួយ*

អត្រាឆ្លងភូមិសិក្សារបស់សិស្សពីបឋមសិក្សា ទៅចូលរៀននៅមធ្យមសិក្សាបឋមភូមិ ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានការកើនឡើងប្រមាណ ១% បើធៀបនឹងឆ្នាំសិក្សា២០១៥-២០១៦ ដោយឡែកសិស្សស្រីមានការថយចុះ ។ លទ្ធផលសម្រេចបាន ៨៨.៨0% បើធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៥-២០១៧ សម្រេចចំណុចដៅ។

លទ្ធផលសិក្សារបស់សិស្សអាហារូបករណ៍ ឆ្នាំសិក្សា២០១៦-២០១៧

| ល.រ | បរិយាយ | អត្រារំហូរសិស្ស ថ្នាក់ទី៤ | | | អត្រារំហូរសិស្ស ថ្នាក់ទី៥ | | | អត្រារំហូរសិស្ស ថ្នាក់ទី៦ | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ឡើង | ត្រួត | បោះបង់ | ឡើង | ត្រួត | បោះបង់ | ឡើង | ត្រួត | បោះបង់ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១ | បរិបូណ៌ | 100% | - | - | 100% | - | - | 100% | - | - |
| ២ | ជលគិរី | 100% | - | - | 100% | - | - | 100% | - | - |
| ៣ | កំពង់ឆ្នាំង | 100% | - | - | 100% | - | - | 100% | - | - |
| ៤ | កំពង់លែង | 100% | - | - | 100% | - | - | 100% | - | - |
| ៥ | កំពង់ត្រឡាច | 97.95% | 2.05% | - | 99.04% | 0.96% | - | 97.97% | 2.03% | 0.34% |
| ៦ | រលាប្អៀរ | 100% | - | - | 100% | - | - | 100% | - | - |
| ៧ | សាមគ្គីមានជ័យ | 98.45% | 1.55% | - | 99.20% | 0.80% | - | 99.21% | 0.79% | - |
| ៨ | ទឹកផុស | 100% | - | - | 100% | - | - | 100% | - | - |
| **សរុបរួម** | | **99.34%%** | **0.66%** | **-** | **99.69%** | **0.31%** | **-** | **99.53%** | **0.47%** | **-** |

*ប្រភពទិន្នន័យៈ ការិយាល័យបឋមសិក្សា*

លទ្ធផលសិក្សារបស់សិស្សអាហារូបករណ៍ឆ្នាំសិក្សា២០១៦-២០១៧ ថ្នាក់ទី៤ ៥ និង៦ សម្រេចបានអត្រាឡើងថ្នាក់ប្រមាណជាង៩៩% មានសិស្សរៀនត្រួតថ្នាក់តិចតួចជាពិសេសមិនមានសិស្សបោះបង់ការសិក្សា លទ្ធផលនេះបានឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា ។

លទ្ធផលនៃការធ្វើតេស្តចុងឆ្នាំសិក្សា និងការជួយសិស្សរៀនយឺតថ្ងៃព្រហស្បតិ៍

| ល.រ | ក្រុង ស្រុក | ចំនួនសិស្សរៀនយឺតដើមឆ្នាំសិក្សា ២០១៦-២០១៧ | | លទ្ធផលជួយសិស្សរៀនយឺតប្រចាំឆ្នាំសិក្សា ២០១៦-២០១៧ | | ចំនួនសិស្សធ្លាក់ចុងឆ្នាំសិក្សា ២០១៦-២០១៧ | | លទ្ធផលតេស្តចុងឆ្នាំសិក្សា ២០១៦-២០១៧ | |
|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | % សរុប | % ស្រី | សរុប | ស្រី | % សរុប | % ស្រី |
| ១ | កំពង់ឆ្នាំង | 910 | 340 | 95.69% | 96.11% | 194 | 86 | 4.31% | 3.89% |
| ២ | រលាប្អៀរ | 2,955 | 1,206 | 93.9% | 96.11% | 830 | 261 | 6.10% | 3.89% |
| ៣ | កំពង់ត្រឡាច | 3,405 | 1,385 | 91.46% | 93.61% | 1138 | 410 | 8.54% | 6.39% |
| ៤ | ទឹកផុស | 2,019 | 845 | 95.53% | 96.95% | 404 | 133 | 4.47% | 3.05% |
| ៥ | បរិបូណ៌ | 1,835 | 725 | 90.63% | 93.08% | 800 | 292 | 9.37% | 6.92% |
| ៦ | សាមគ្គីមានជ័យ | 4,982 | 2,764 | 91.64% | 94.20% | 964 | 325 | 8.38% | 5.80% |
| ៧ | កំពង់លែង | 1,672 | 864 | 90.39% | 92.39% | 753 | 299 | 9.61% | 7.61% |
| ៨ | ជលគីរី | 1,359 | 706 | 87.29% | 88.96% | 743 | 313 | 12.71% | 11.04% |
| **សរុប** | | **19,137** | **8,835** | **92.15%** | **94.16%** | **5826** | **2119** | **7.85%** | **5.84%** |

*ប្រភពទិន្នន័យៈ ការិយាល័យបឋមសិក្សា*

លទ្ធផលនៃការជួយសិស្សរៀនយឺតថ្ងៃព្រហស្បតិ៍សម្រេចបានប្រមាណ ៩២.១៥% ស្រី ៩៤.១៦% និងលទ្ធផលនៃការធ្វើតេស្តចុងឆ្នាំសិក្សា២០១៦-២០១៧

សម្រេចបានប្រមាណតែជិត៨% ស្រីប្រមាណ ៦% ប៉ុណ្ណោះ ចំណែកឯសិស្សធ្លាក់តេស្តចុងឆ្នាំសិក្សាមានសរុប ៥៨២៦នាក់ ស្រី២១១៩នាក់ ។ ជាមួយគ្នាដែរនេះសម្រាប់ដើមឆ្នាំសិក្សា២០១៧-២០១៨ នេះ លទ្ធផលសិស្សជាប់តេស្តដើមឆ្នាំសិក្សាសម្រេចបានប្រមាណ៩២.១៥% ស្រី៩៤.១៦% ។

### ក.១.៤.ការប្រែប្រួលលើផ្នែកគុណភាពនៃសេវាអប់រំ

លទ្ធផលនៃការសិក្សាបរិស្ថានសិក្សា និង ការផ្គត់ផ្គង់សៀវភៅសិក្សាគោល

| បរិយាយ | ឆ្នាំសិក្សា ២០១៥-២០១៦ | | ឆ្នាំសិក្សា ២០១៦-២០១៧ | | កើន-ថយ (+/-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ផលធៀបសិស្ស គ្រូតំបន់ប្រជុំជន | 27.1 | | 38.65 | | +11.55 | |
| ផលធៀបសិស្ស គ្រូ តំបន់ជនបទ | 42.5 | | 45.17 | | +2.42 | |
| ផលធៀបសិស្ស ថ្នាក់ | 49.8 | | 33.41 | | -16.36 | |
| ផលធៀបសៀវភៅ សិស្ស ថ្នាក់ទី១-៣ | 2 / 1 | | 3 / 1 | | +1 | |
| ផលធៀបសៀវភៅ សិស្ស ថ្នាក់ទី៤-៦ | 3 / 1 | | 4 / 1 | | +1 | |
| ចំនួនសាលារៀនដែលសិស្សមាន លទ្ធភាពសិក្សាក្នុងបណ្ណាល័យ | 111សាលា | | 115សាលា | | +4 | |
| ចំនួនបណ្ណារក្សដែលបានទទួលការបណ្តុះបណ្តាល | 84នាក់ លើ117នាក់ | | 84នាក់ លើ117នាក់ | | -»- | |

*ប្រភពទិន្នន័យ៖ការិយាល័យ បឋមសិក្សា*

ក្នុងឆ្នាំសិក្សា២០១៦-២០១៧កន្លងទៅនេះ ជាមធ្យមគ្រូបង្រៀនម្នាក់បង្រៀនសិស្ស៣៦នាក់ នៅតំបន់ប្រជុំជន(ក្រុងកំពង់ឆ្នាំង) បានបង្ហាញថាចំនួនគ្រូបង្រៀននៅបន្តលើសនៅតំបន់ប្រជុំជន និងនៅតំបន់ជនបទ គ្រូបង្រៀនម្នាក់បង្រៀនសិស្សប្រមាណ ៤៥នាក់ ។ ចំនួនបន្ទប់មានការកើនឡើងតិចតួច ជាមធ្យមចំណុះសិស្សក្នុង១ថ្នាក់ប្រមាណ៣៤នាក់ ។

ការផ្គត់ផ្គង់សៀវភៅសិក្សាគោលក្នុងឆ្នាំសិក្សា២០១៦-២០១៧ កន្លងទៅនេះ សិស្សថ្នាក់ទី១-៣ ជាមធ្យមសិស្ស១នាក់ ទទួលបានសៀវភៅ៣ក្បាល សិស្សថ្នាក់ទី៤-៦ ជាមធ្យមសិស្ស១នាក់ ទទួលបានសៀវភៅ៤ក្បាល ។ជាមួយគ្នានេះដែរ សាលារៀនមានបណ្ណាល័យ និងបានបង្កលក្ខណៈឱ្យសិស្សបានសិក្សាក្នុងបណ្ណាល័យ

មានចំនួន ១១៥ សាលា លើ២៧៣សាលា ស្មើនឹង៤២% លទ្ធផលសម្រេចបានគឺកើនពីឆ្នាំសិក្សា២០១៥-២០១៦ ។

### ក.១.៥. ការអនុវត្តកម្មវិធីសិក្សានិងការសម្រេចបានម៉ោងសិក្សាប្រចាំឆ្នាំ

- សាលារៀន
  នៅតំបន់ជួបការលំបាកអនុវត្តកម្មវិធីសិក្សាបានត្រឹម៨០%ចំពោះសាលារៀននៅទីប្រជុំជនអនុវត្តបាន១០០% នៃកម្មវិធីសិក្សាគោលថ្នាក់ជាតិ
- សាលារៀននៅតំបន់ជួបការលំបាក អនុវត្តបានពី៦០០ម៉ោងទៅ៧០០ម៉ោង ចំពោះសាលារៀននៅទីប្រជុំជនអនុវត្តបានពី៨០០ម៉ោងទៅ១០០០ម៉ោងក្នុងមួយឆ្នាំសិក្សា។

### ក.១.៦. គុណវុឌ្ឍគ្រូបង្រៀន

- គ្រូបង្រៀនបឋមសិក្សាភាគច្រើន បានបង្កើនសមត្ថភាពចំណេះដឹងទូទៅនៅ សាលាបំពេញវិជ្ជារៀបរយខេត្ត មហាវិទ្យាល័យ និងវិទ្យាស្ថាននានា
- គ្រូបង្រៀនបឋមសិក្សាបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០១៦-២០១៧ មានចំនួន១២នាក់ ស្រី០១នាក់
- គ្រូបង្រៀនបឋមសិក្សាទទួលបានសញ្ញាបត្របរិញ្ញាបត្រចំនួន៦២នាក់ ស្រី២៥នាក់ ។

## ក.២. ឆានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

### ក.២.១ ការអភិវឌ្ឍសមត្ថភាព

- មន្ត្រីទទួលបន្ទុកប្រពន្ធ័ពិនិត្យតាមដានផ្អែកលើអនុវិស័យបឋម ថ្នាក់មន្ទីរ ក្រុង/ស្រុក ចំនួន ២៨ នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រពន្ធ័ពិនិត្យតាមដានផ្អែកលើអនុវិស័យបឋម
- បានបំប៉នផ្តល់អាហាររូបករណ៍ដល់មន្ត្រីទទួលបន្ទុកតាមក្រុងស្រុកចំនួន១ លើក ដែលមានសិក្ខាកាមចូលរួម ចំនួន៧៨ នាក់។គ្រូថ្នាក់ទី ១-៣ និងមន្ត្រីការិយាល័យអប់រំស្រុក (១នាក់ក្នុង១ស្រុក) សរុបរួម ១២៣នាក់ បានចូលរួម វគ្គបណ្តុះបណ្តាលស្តង់ដាអំណានទី១-៣
- នាយកសាលាចំនួន ៤៧ សាលា បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវឌ្ឍនភាពសាលារៀនប្រចាំត្រីមាស
- សហគនម៍ លោកគ្រូ អ្នកគ្រូ តំណាងក្រុមប្រឹក្សា កុមារចំនួន ៦២នាក់ បានចូលរួមសិក្ខាសាលាស្តីពីការរៀបចំក្រុមប្រឹក្សាភិបាលប្រចាំសាលារៀន និងពង្រឹង ការងារ តួនាទី ភារកិច្ចរបស់សាលារៀន មាតាបិតា និងសហគមន៍ក្នុងដំណើរការរៀនរបស់កុមារ

- នាយក នាយករង លោកគ្រូ អ្នកគ្រូ តំណាងសហគមន៍ និងតំណាងក្រុមប្រឹក្សាកុមារ សរុបរួមចំនួន ១១៥ នាក់ បានចូលរួមវគ្គសិក្ខាសាលាស្តីពីគុណភាពសាលាកុមារមេត្រី
- យុវជនស្ម័គ្រចិត្ត ២០នាក់បានទទួលការអភិវឌ្ឍសមត្ថភាពលើវិធីសាស្រ្តបង្រៀន ការប្រមូលទិន្នន័យ គាំទ្រក្លឹបកុមារ និងយុវជន ឧបត្ថម្ភដោយអង្គការ WVI-C
- គ្រូបង្រៀន ៣៨នាក់ បានអនុវត្តគរុកោសល្យបត់បែនបង្កើនគុណភាពបង្រៀន និងបរិយាកាសកុមារមេត្រី ឧបត្ថម្ភដោយអង្គការ SC
- នាយកសាលារៀនគោលដៅ ១៨នាក់ បានទស្សនកិច្ចសិក្សាសាលាជំនាន់ថ្មី នៅខេត្តកំពង់ចាមនាយក គ្រូបង្រៀន ១៦៥នាក់ បានបណ្តុះបណ្តាលបច្ចេកទេសបង្រៀន និងវិធីសាស្រ្តបង្កើតសម្ភារបង្រៀន នាយក គ្រូបង្រៀន ១០៣នាក់ បានបណ្តុះបណ្តាលពីសិទ្ធិកុមារ និងការពារកុមារ នាយក គ្រូបង្រៀន ៥០នាក់ បានបណ្តុះបណ្តាលពីភាពជាអ្នកដឹកនាំ តម្លាភាព និងការទទួលខុសត្រូវ មន្រ្តីការិយាល័យអប់រំ យុវជន និងកីឡាស្រុក ១៨នាក់ បានបណ្តុះបណ្តាលពី ការប្រមូល និងវិភាគទិន្នន័យ ឧបត្ថម្ភដោយអង្គការ KAPE
- នាយកសាលាចំនួន៤៧ នាក់ និងគ្រូបង្រៀនថ្នាក់ទី ១ ទី២ ទី៣ សរុបរួមចំនួន១៦៨នាក់ ក្នុងសាលាគោលដៅរបស់អង្គការSC បានចូលរួមវគ្គបណ្តុះបណ្តាលស្តីការងារបច្ចេកទេសបង្រៀន និងរៀនដោយប្រើប្រាស់សៀវភៅស្តង់ដាអំណាន ឧបត្ថម្ភដោយអង្គការ SC
- នាយកសាលាចំនួន ២៦នាក់ បានចូលរួមសិក្ខាសាលាការរៀបចំផែនការផ្អែកលើលទ្ធផល (RSDP) និងនាយកសាលាចំនួន ១៤នាក់ បានចូលរួមសិក្ខាសាលា ការប្រើប្រាស់ទិន្នន័យ និងវិភាគស្ថិតិអប់រំ ឧបត្ថម្ភដោយថវិកាមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព(CDPF)
- បានប្រជុំផ្សព្វផ្សាយ ប្រកាសអន្តរក្រសួងលេខ ៥២៣ សហវ ប្រក ចុះថ្ងៃទី ០៩ខែ ឧសភា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជូននាយកសាលារៀនបាន ២៧៣នាក់។

### ក.២.២ ការពិនិត្យតាមដាន

- ពិនិត្យតាមដានលើការងារគ្រប់គ្រង ដឹកនាំ និងការងារបច្ចេកទេសបង្រៀន និងរៀន បានចំនួន ១២២សាលា លើ២៧៣សាលា គិតជាភាគរយស្មើនឹង

៤៣.៩៥% ដោយក្នុងនោះសាលាចំនួន ៥៦%នៃសាលា១២២ បានធ្វើស្វ័យសិក្សាទាំងនាយក ទាំគ្រូតាមថ្នាក់គ្រូ៩៨%មិនបានប្រើប្រាស់សៀវភៅស្តង់ដារអំណានដែលក្រសួង មន្ទីរ បានចែកជូនទេ ដោយហេតុពួកគាត់មិនចេះពីរបៀបប្រើប្រាស់សៀវភៅនេះទេ គ្រូចំនួន៨៥.៤២% គ្មានកិច្ចតែងការ (គ្រូសរុបនៃសាលាចំនួន ៣៧សាលាដែលក្រុមការងារបានចុះពិនិត្យតាមដាន)

- បានពិនិត្យតាមដានការអនុវត្តកម្មវិធីលើកកម្ពស់សុខភាពសិក្សាតាមសាលារៀនបឋមសិក្សាចំនួន ៣០ សាលារៀន ការអនុវត្តគម្រោងអនាម័យគំរូ នៅតាមសាលារៀនបឋមសិក្សាចំនួន ២០ ប្រើប្រាស់ថវិកា UNICEF និងពិនិត្យសុខភាពសិស្សថ្នាក់ទី១ ២៧៣សាលារៀន ប្រើប្រាស់ថវិកាគាំទ្រវិស័យអប់រំទី២
- បានពិនិត្យតាមដាន និងកែលម្អ ការគ្រប់គ្រងស្ថិតិអប់រំ និងការកសាងផែនការអភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំ នៅតាមសាលារៀនបឋមសិក្សាចំនួន ៧៨
- បានពិនិត្យតាមដានការងារគ្រប់គ្រងបុគ្គលិក នៅសាលារៀនបឋមសិក្សាចំនួន ២២
- បានពិនិត្យតាមដានការអនុវត្តថវិកា (កិច្ចបញ្ជិកាគណនេយ្យ ហិរញ្ញកិច្ច និងសម្ភារ ឯកសារទូទាត់ថវិកា ការទុកឯកសារទូទាត់ ) តាមសាលារៀនបឋមសិក្សាចំនួន ២៧៣ និងការងារទ្រព្យសម្បត្តិរដ្ឋ ចំនួន ៦០សាលា
- បានចុះពិនិត្យតានដានលើការគ្រប់គ្រងការងាររដ្ឋបាលនៅតាមសាលារៀនបឋមសិក្សាចំនួន ២១ ។

## ខ.ទិន្នន្នភាពនៃការសម្រេចបានសូចនាករអនុវិស័យការអប់រំបឋមសិក្សា




គោលនយោបាយទី១ មានសូចនាករសរុប ១៩ ក្នុងនោះសម្រេចចំណុចដៅឆ្នាំសិក្សា២០១៧-២០១៨(បច្ចុប្បន្នភាពESP 2015-2017) មាន ៦សូចនាករ ស្មើនឹង ៣២% លទ្ធផលអាចទទួលយកបាន ៧សូចនាករ ស្មើនឹង ៣៦%

និងមិនសម្រេចចំណុចដៅ៦ សូចនាករស្មើនឹង ៣២% (ពាក់ព័ន្ធនឹងការចូលរៀន)។ (ឧបសម្ព័ន្ធទី៤)

**គ.បញ្ហាប្រឈម**

- សមត្ថភាពរបស់គ្រូបង្រៀន ពីរថ្នាក់ ពីរពេល និងថ្នាក់គួប សមត្ថភាពគ្រប់គ្រងផ្អែកលើលទ្ធផល របស់នាយកសាលារៀនមួយចំនួន និងសមត្ថភាពនាយក គ្រូបង្រៀនអំពី ការប្រើប្រាស់សៀវភៅ ស្តង់ដាអំណាន
- ខ្វះអគារសិក្សា នៅសាលាបឋមសិក្សា អន្លង់អក ស្រុកជលគិរី សាលាបឋមសិក្សាប្រាសាទ ចំបក់ខ្ពស់ ពោធិអណ្តែត ស្រុកកំពង់លែង សាលាបឋមសិក្សាព្រះធាតុ ស្រុករលាប្អៀរ
- ការងារគ្រប់គ្រងរបស់នាយកសាលាមួយចំនួន មិនទាន់មានភាពម៉ឺងម៉ាត់ និងការបំពេញតួនាទី និងភារកិច្ចរបស់គណៈកម្មការនានារបស់សាលារៀន
- និយ័តភាពការងាររបស់នាយក និងគ្រូបង្រៀនមួយចំនួន (នាយកបង្រៀនផង និងគ្រប់គ្រងផង ការគោរពពេលវេលា/ម៉ោងបង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ...)។

ជារួម ការចូលរៀនរបស់កុមារអាយុ ៦ឆ្នាំ ការរក្សាសិស្សអាយុ៦-១១ឆ្នាំនៅកម្រិតបឋមសិក្សា ការបញ្ចប់ការសិក្សារបស់សិស្ស ក្នុងឆ្នាំសិក្សា២០១៧-២០១៨នេះ មានការថយចុះ ទន្ទឹមនឹងការបោះបង់ការសិក្សាមានការកើនឡើង និងការត្រួតថ្នាក់ក្នុងឆ្នាំសិក្សា២០១៦-២០១៧ បានកាត់បន្ថយតិចតួច ដោយឡែកអត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ មានការកើនឡើងក្នុងកម្រិតតែ ១%ប៉ុណ្ណោះ។ លទ្ធផលខាងលើ ជាព័ត៌មានមិនអាចខ្វះបាន សម្រាប់កំណត់គោលដៅ និងក្រុមមុខសញ្ញា សម្រាប់អន្តរាគមន៍ក្នុងឆ្នាំសិក្សា២០១៧-២០១៨ ផ្តោតលើគុណភាពគ្រូ និងលទ្ធផលសិក្សារបស់សិស្ស។

## ២.៣ អនុវិស័យការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស

### ក.លទ្ធផលសម្រេចបាន

**ក.១. ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា**

ស្ថិតិសាលារៀន បន្ទប់ ថ្នាក់ សិស្ស និងគ្រូបង្រៀន

| ល.រ | បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | ឆ្នាំសិក្សា ២០១៧-២០១៨ | កើន-ថយ (+/-) |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| **អនុវិទ្យាល័យ** | | | | |
| ១ | ចំនួនសាលារៀន | 60 | 60 | -ដ- |
| ២ | ចំនួនឃុំមានអនុវិទ្យាល័យ | 66 | 66 | -ដ- |
| ៣ | ចំនួនថ្នាក់រៀន | 322 | 326 | +4 |
| ៤ | ចំនួនបន្ទប់រៀន | 288 | 302 | +14 |
| ៥ | ចំនួនសិស្សសរុប | 15,390 | 15,342 | -48 |
| ៦ | ចំនួនសិស្សស្រីសរុប | 8315 | 8170 | -145 |
| ៧ | ចំនួនបុគ្គលិកបង្រៀនសរុប | 591 | 516 | -75 |
| ៨ | ចំនួនបុគ្គលិកបង្រៀនស្រី | 268 | 246 | -22 |
| ៩ | ចំនួនបុគ្គលិកអប់រំសរុប | 674 | 665 | -9 |
| ១០ | ចំនួនបុគ្គលិកអប់រំស្រី | 291 | 288 | -3 |
| ១១ | ចំនួនសិស្សអាហារូបករណ៍សរុប (ថវិកាកម្មវិធី) | 3075 | 3214 | +139 |
| ១២ | ចំនួនសិស្សអាហារូបករណ៍ស្រី (ថវិកាកម្មវិធី) | 1840 | 1921 | +81 |
| **វិទ្យាល័យ (ថ្នាក់ទី ៧- ១២)** | | | | |
| ១ | ចំនួនសាលារៀន | 16 | 16 | -ដ- |
| ២ | ចំនួនថ្នាក់រៀន | 415 | 439 | +24 |
| ៣ | ចំនួនបន្ទប់រៀន | 393 | 404 | +11 |
| ៤ | ចំនួនសិស្សសរុប | 19,990 | 21,355 | +1365 |
| ៥ | ចំនួនសិស្សស្រីសរុប | 10,619 | 11,501 | +882 |
| ៦ | ចំនួនបុគ្គលិកបង្រៀនសរុប | 976 | 950 | -26 |
| ៧ | ចំនួនបុគ្គលិកបង្រៀនស្រី | 351 | 345 | -6 |
| ៨ | ចំនួនបុគ្គលិកអប់រំសរុប | 1131 | 1127 | -4 |
| ៩ | ចំនួនបុគ្គលិកអប់រំស្រី | 392 | 398 | +6 |
| ១០ | ចំនួនសិស្សអាហារូបករណ៍សរុប (ថវិកាកម្មវិធី) | 360 | 540 | +180 |
| ១១ | ចំនួនសិស្សអាហារូបករណ៍ស្រី (ថវិកាកម្មវិធី) | 216 | 324 | +108 |
| **ការអប់រំបច្ចេកទេស** | | | | |
| ១ | ចំនួនគ្រូបង្រៀនអប់រំបច្ចេកទេស | 32 / 7 | 35 / 9 | +3 / +2 |
| ២ | ចំនួនថ្នាក់រៀន | 07 | 08 | +1 |
| ៣ | ចំនួនសិស្សអប់រំបច្ចេកទេស (សរុប) | 222 | 240 | +22 |
| ៤ | ចំនួនសិស្សអប់រំបច្ចេកទេស (ស្រី) | 97 | 94 | -3 |
| ៥ | ចំនួនសិស្សឯកទេសក្សេត្រសាស្ត្រ | 92 / 62 | 92/64 | ដ/ +2 |
| ៦ | ចំនួនសិស្សឯកទេស អគ្គីសនី | 118 / 26 | 126/18 | +8 / -8 |
| ៧ | ចំនួនសិស្សឯកទេស បសុវប្បកម្ម | 12 / 09 | 22/12 | +10 / +3 |

*ប្រភពទិន្នន័យ: ការិយាល័យមធ្យមសិក្សានិងចំណេះទូទៅ*

ក្នុងឆ្នាំសិក្សា២០១៧-២០១៨នេះ ចំនួនសិស្សរៀននៅអនុវិទ្យាល័យមានការថយចុះ ដោយឡែកនៅវិទ្យាល័យមានការកើនឡើងរហូតដល់ ១៣៦៥នាក់ ស្រី៨៨២នាក់ ជាមួយគ្នានេះ ការចូលរៀនរបស់សិស្សនៅសាលាមធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេស ផ្នែកបច្ចេកទេសមានការកើនឡើងតិចតួចប្រមាណ ២២នាក់ ។

សង្កាត់២ នៅក្រុងកំពង់ឆ្នាំង(សង្កាត់ប្អេរនិងសង្កាត់ផ្សារឆ្នាំង) លើ៧០ឃុំ /សង្កាត់ ស្មើនឹង២.៨៥%មិនទាន់មានលទ្ធភាពបង្កើតអនុវិទ្យាល័យនៅឡើយដោយសារស្ថានភាព ភូមិសាស្ត្រ និង កង្វះដីសម្រាប់សាងសង់។

សាលារៀនចំនួន៣៧បានទទួលកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ លើ៧៦សាលានៅទូទាំងខេត្ត ។ចំនួនសិស្សអាហារូបករណ៍នៅអនុវិទ្យាល័យក្នុងឆ្នាំសិក្សា២០១៧-២០១៨នេះមានការកើនឡើងប្រមាណ ១៣៩នាក់ ស្រី៨១នាក់ និងនៅវិទ្យាល័យក៏មានការកើនឡើងផងដែរប្រមាណ ១៨០នាក់ ស្រី១០៨នាក់ ។

រូបភាពទី១០៖ អត្រារួមនៃការសិក្សាមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិឆ្នាំសិក្សា២០១៧-២០១៨ ធៀបនឹងចំណុចដៅបច្ចុប្បន្នភាពESP 2015-2017




*ប្រភពទិន្នន័យ៖ EMIS 2017-2018*

ការចូលរៀននៅមធ្យមសិក្សាបឋមភូមិ ក្នុងឆ្នាំសិក្សា២០១៧-២០១៨មានការកើនឡើងតិចតួច បើធៀបនឹងឆ្នាំសិក្សា២០១៦-២០១៧ ជាមួយគ្នានេះ ការចូលរៀននៅមធ្យមសិក្សាទុតិយភូមិ មានការកើនឡើងប្រមាណ ២.៤% ប៉ុណ្ណោះ ក្នុងឆ្នាំសិក្សា២០១៧-២០១៨។ លទ្ធផលនៃការចូលរៀននៅមធ្យមសិក្សាបឋមភូមិ ធៀបនឹងចំណុចដៅឆ្នាំសិក្សា២០១៧-២០១៨ នៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៥-២០១៧ គឺលទ្ធផលនៅកៀកនឹងចំណុចដៅ ។

### រូបភាពទី១១៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ឆ្នាំសិក្សា២០១៧-២០១៨




*ប្រភពទិន្នន័យ៖ EMIS 2017-2018*

អត្រាបញ្ចប់ការសិក្សារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិ មានការកើនឡើងប្រមាណ ៣.៥% នៅឆ្នាំសិក្សា២០១៧-២០១៨នេះ ធៀបនឹងឆ្នាំសិក្សា២០១៦-២០១៧ ។ លទ្ធផលសម្រេចបាន ៥០.៧៤% បើធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៥-២០១៧ ៥២% លទ្ធផលនៅកៀកនឹងចំណុចដៅ។ ជាមួយគ្នានេះដែរ អត្រាបញ្ចប់ការសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិក៏មានការកើនឡើងប្រមាណ ២.២% ផងដែរនៅឆ្នាំសិក្សា២០១៧-២០១៨នេះ៖ និន្នាការនេះបានឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅមធ្យមសិក្សា។

### លទ្ធផលសិក្សារបស់សិស្ស និងការផ្គត់ផ្គង់សៀវភៅសិក្សាគោល

| បរិយាយ | ឆ្នាំសិក្សា ២០១៥-២០១៦ | | ឆ្នាំសិក្សា ២០១៦-២០១៧ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |

| | | | | | | |
|---|---|---|---|---|---|---|
| **មធ្យមសិក្សាបឋមទួមិ** | | | | | | |
| អត្រាឡើងថ្នាក់ | 84.3 | 86.5 | 84.9 | 87.2 | +0.6 | +0.7 |
| អត្រាត្រួតថ្នាក់ | 1.9 | 1.1 | 1.7 | 0.7 | -0.2 | -0.4 |
| អត្រាបោះបង់ | 13.8 | 12.4 | 13.4 | 12,1 | -0.4 | -0.3 |
| % ប្រឡង DESPC | 96.70 | 98.06 | 97.31 | 98.62 | +0.61 | +0.56 |
| ផលធៀបសិស្ស-គ្រូ | 23.4 | | 25.3 | | +1.9 | |
| ផលធៀបសិស្ស-ថ្នាក់ | 48.4 | | 48.0 | | -0.4 | |
| ផលធៀបសៀវភៅសិក្សា-សិស្ស | ៥ក្បាលក្នុង១នាក់ | | ៥ក្បាលក្នុង១នាក់ | | -ដ- | |
| **មធ្យមសិក្សាទុតិយទួមិ** | | | | | | |
| អត្រាឡើងថ្នាក់ | 75.1 | 77.1 | 76.9 | 79.2 | +1.8 | +2.1 |
| អត្រាត្រួតថ្នាក់ | 2.9 | 2.2 | 3.0 | 1.9 | +0.1 | -0.3 |
| អត្រាបោះបង់ | 22.0 | 20.6 | 20.1 | 18.9 | -1.9 | -1.7 |
| % សិស្សប្រឡងជាប់Bac II | 57.70 | 61.01 | 54.46 | 56.97 | -3.24 | -4.04 |
| ផលធៀបសិស្ស-គ្រូ | 20.5 | | 20.4 | | -0.1 | |
| ផលធៀបសិស្ស-ថ្នាក់ | 46.9 | | 47.7 | | +0.8 | |
| ផលធៀបសៀវភៅសិក្សា-សិស្ស | ៧ក្បាលក្នុង២នាក់ | | ១០ក្បាលក្នុង២នាក់ | | -ដ- | |

អត្រាបោះបង់ការសិក្សាខ្ពស់នៅមធ្យមសិក្សាទុតិយភូមិ ដោយសារសិស្សបោះបង់ការសិក្សាទៅធ្វើការនៅរោងចក្រ រៀបការ ។ភាគរយសិស្សបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានការថយចុះប្រមាណ ៣.២% ទិន្នាការមានកត្តាពាក់ព័ន្ធមួយចំនួនមានកង្វះគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅតំបន់ជនបទ និងការជ្រើសរើសបណ្តុំមុខវិជ្ជារបស់សិស្សថ្នាក់១២ (មុខវិជ្ជា វិទ្យាសាស្ត្រ) ។

រូបភាពទី១២៖ អត្រារំហូរសិស្ស នៅមធ្យមសិក្សាបឋមភូមិឆ្នាំសិក្សា២០១៦-២០១៧ ធៀបនឹងចំណុចដៅបច្ចុប្បន្នភាព ESP 2015-2017




*ប្រភពទិន្នន័យ៖ EMIS 2017-2018*

អត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ មានការថយចុះតិចតួច ក្នុងឆ្នាំសិក្សា២០១៦-២០១៧ ។ លទ្ធផលអត្រាបោះបង់ការសិក្សាសម្រេចបាន ១៣.៤% បើធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៥-២០១៧ ១១% លទ្ធផលនៅកៀកនឹងចំណុចដៅ ។

រូបភាពទី១៣៖ អត្រារំហូរសិស្ស នៅមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០១៦-២០១៧




*ប្រភពទិន្នន័យ៖ EMIS 2017-2018*

អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិមានការថយចុះប្រមាណ ១.៩% នៅឆ្នាំសិក្សា២០១៦-២០១៧នេះ ទន្ទឹមនិងអត្រាឡើងថ្នាក់មានការកើនឡើងជិត២% តែអត្រាត្រួតថ្នាក់មានការកើនឡើងតិចតួច ។

រូបភាពទី១៥៖ អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា ២០១៦-២០១៧




*ប្រភពទិន្នន័យ៖ EMIS 2017-2018*

អត្រាឆ្លងភូមិសិក្សារបស់សិស្សពីមធ្យមសិក្សាបឋមភូមិទៅទុតិយភូមិ មានការកើនឡើងប្រមាណ ១% ប៉ុណ្ណោះនៅឆ្នាំសិក្សា២០១៦-២០១៧ ចំពោះសិស្សស្រី មានការកើនឡើងប្រមាណ ១% ផងដែរ ។ លទ្ធផលសម្រេចបាន ៧៥.៦% ស្រី ៧៧.២% បើធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៥-២០១៧ ៧៧% ស្រី៧៩% លទ្ធផលនៅកៀកចំណុចដៅ ។

## ការអនុវត្តកម្មវិធីសិក្សានិងការសម្រេចបានម៉ោងសិក្សាប្រចាំឆ្នាំ

- សាលាមធ្យមសិក្សាភាគច្រើនអនុវត្តម៉ោងសិក្សាបានពី២៨ ទៅ ៣២ម៉ោងក្នុងមួយសប្តាហ៍ឬ ៩៨៦ ទៅ ១០៨៨ ម៉ោងក្នុងមួយឆ្នាំសិក្សា ស្មើ៨៥ភាគរយទៅ៩២ភាគរយ នៃម៉ោងសិក្សាកំណត់ក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ។ថ្នាក់ទី៩ និងទី១២ អនុវត្តបាន១០០ភាគរយ ចំណែកថ្នាក់ទី៧-៨-១០-១១ អនុវត្តបាន៨៧ភាគរយ ទៅ ៩៨ភាគរយ
- ការបង្រៀនតាមមុខវិជ្ជានីមួយៗបានផ្តោតទៅលើ ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល និងការប្រើប្រាស់សម្ភារឧទ្ទេស ។ វិទ្យាល័យធនធាន និងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស បានដំណើរការរៀននិងបង្រៀនដោយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើផ្នែកកុំព្យូទ័រ ពិសោធន៍ផ្នែកវិទ្យាសាស្ត្របច្ចេកទេស និងស្រាវជ្រាវក្នុងបណ្ណាល័យ ។

## ការអនុវត្តកម្មវិធីសាលាកុមារមេត្រី

- សាលាមធ្យមសិក្សាបានអនុវត្តកម្មវិធីសាលាកុមារមេត្រី និង បរិស្ថានសាលារៀនមានកម្រិតអភិវឌ្ឍន៍៩.៥% កម្រិតមធ្យម ៦៧% កម្រិតមូលដ្ឋាន២៣.៥%
- សាលារៀនដែលបានរៀបចំផែនការអភិវឌ្ឍសាលារៀនដោយកំណត់គោលបំណងច្បាស់លាស់គ្រប់ជ្រុងជ្រោយនិងអនុវត្តបានលទ្ធផលល្អមាន៣៥% ស្ថិតក្នុងកម្រិតល្អបង្គួរមាន៣៤% កម្រិតមធ្យមប្រមាណ ២១% និងស្ថិតក្នុងកម្រិតខ្សោយមិនអាចអនុវត្តបានមានប្រមាណ១០% ដែលភាគច្រើនជាសាលារៀនទើបបង្កើតថ្មីនិងស្ថិតនៅតំបន់ជួបការលំបាក។

### លទ្ធផលប្រឡងជ្រើសរើសសិស្សពូកែ

- បានប្រឡងជ្រើសរើសជ័យលាភីសិស្សពូកែទូទាំងខេត្តចំនួន១៨នាក់ស្រី៩ នាក់ លើបេក្ខជន២០៧នាក់ ស្រី១២៥នាក់ផ្នែកអក្សរសិល្ប៍ខ្មែរគណិតវិទ្យានិងរូបវិទ្យាថ្នាក់ទី៩និងទី១២ដើម្បីចូលរួមប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស នៅខេត្តបាត់ដំបង
- បានទទួលជ័យលាភីសិស្សពូកែទូទាំងប្រទេសចំនួន៤នាក់ ស្រី២នាក់ ( គណិតវិទ្យាថ្នាក់ទី៩ ចំនួន១នាក់ស្រី០នាក់ , រូបវិទ្យាថ្នាក់ទី៩ ចំនួន២នាក់ ស្រី២នាក់ រូបវិទ្យាថ្នាក់ទី១២ចំនួន១នាក់ ស្រី០នាក់ )
- សិស្សទទួលបាននិទ្ទេសAនៅក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំនួន១២នាក់ ស្រី ៤នាក់
- បានបញ្ជូនសិស្សពូកែ រូបវិទ្យាថ្នាក់ទី៩ ចំនួន២នាក់ ស្រី២នាក់ ទៅបំប៉ននៅភ្នំពេញដើម្បីត្រៀមចូលរួមប្រកួតប្រជែងអ្នកវិទ្យាសាស្ត្រវ័យក្មេងអូឡាំព្យាដអន្តរជាតិលើកទី១៤នៅប្រទេសហូឡង់ ជាលទ្ធផលសិស្សម្នាក់នៃវិទ្យាល័យព្រះបាទសុរាម្រឹតទទួលបានមេដាយសំរឹទ្ធមួយគ្រឿងក្នុងចំណោមបេក្ខជន៣០០នាក់មកពី៥០ប្រទេស
- បានបញ្ជូនសិស្សពូកែគណិតវិទ្យាថ្នាក់ទី៩ចំនួន២នាក់ ស្រី១នាក់ទៅបំប៉ននៅភ្នំពេញដើម្បីត្រៀមចូលរួមប្រកួតប្រជែង អូឡាំព្យាដអន្តរជាតិលើកទី៥៩នៅប្រទេសរ៉ូម៉ានី
- បានបញ្ជូនសិស្សពូកែរូបវិទ្យាថ្នាក់ទី៩ចំនួន១នាក់ ទៅបំប៉ននៅភ្នំពេញដើម្បីត្រៀមចូលរួមប្រកួតប្រជែងអូឡាំព្យាដទ្វីបអាស៊ីលើកទី១៩នៅប្រទេសវៀតណាម។

### គុណវុឌ្ឍិរបស់គ្រូបង្រៀន

- គ្រូបង្រៀនមធ្យមសិក្សាមួយចំនួនបានទៅរៀនបន្ថែមនៅតាមមហាវិទ្យាល័យនានាព្រមទាំងទទួលបានការបំប៉នលើវិធីសាស្ត្របង្រៀន ភាពជាអ្នកដឹកនាំ ការដឹកនាំក្រុមបច្ចេកទេស
- បានពង្រឹងការអនុវត្តច្បាប់ស្តីពីការអប់រំនិងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនដឹកនាំការប្រជុំធ្វើថ្នាក់និទស្សន៍ ការផលិតសម្ភារឧបទេសតាមមុខវិជ្ជា និងកែលម្អចំណុចខ្វះខាត ឲ្យស្របតាមកម្មវិធីសាលាកុមារមេត្រីនៅមធ្យមសិក្សា ។

## ក.២ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

### ក.២.១ ការអភិវឌ្ឍសមត្ថភាព

- គណៈកម្មការសាលារៀន ១៥នាក់បានចូលរួមប្រជុំតាមដានសិស្សអវត្តមានច្រើន ឧបត្ថម្ភដោយអង្គការSOFDEC
- គណៈកម្មការសាលារៀននិងគ្រូបង្រៀន២០នាក់ បានចូលរួមប្រជុំធ្វើផែនការអភិវឌ្ឍន៍សាលារៀន រាល់៣ខែម្តង ឧបត្ថម្ភដោយអង្គការ SOFDEC
- នាយកសាលាចំនួន ៣៨នាក់បានបំប៉នសមត្ថភាពស្តីពី ការពង្រីក និងពង្រឹងការអនុវត្តការលើកកម្ពស់ការអនុត្តសុខភាពសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ
- នាយកសាលាចំនួន១១នាក់ បានចូលរួមសិក្ខាសាលា ការប្រើប្រាស់ទិន្នន័យ និងវិភាគស្ថិតិអប់រំ នៅកម្រិតសាលារៀន គាំទ្រដោយថវិកាមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព(CDPF)
- នាយកសាលាចំនួន៧៦នាក់ បានចូលរួមប្រជុំផ្សព្វផ្សាយប្រកាសអន្តរក្រសួងលេខ ៥២៣ សហវ ប្រក ចុះថ្ងៃទី ០៩ខែ ឧសភា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ក.២.២ ការពិនិត្យតាមដាន

- បានពិនិត្យតាមដានសាលារៀនចំនួន៣៨សាលា(៨ស្រុក ) ដោយផ្តោតលើការងារគ្រប់គ្រងរដ្ឋបាល ការងារបច្ចេកទេស បណ្ណាល័យមណ្ឌលធនធានបរិស្ថានសាលារៀនការប្រឡងឆមាសទាំងពីរលើកនិងកម្មវិធីសាលាកុមារមេត្រីនៅមធ្យមសិក្សាក្នុងនោះ ៥៨% អនុវត្តបានល្អ ៣០% អនុវត្តបានល្អបង្គួរ និង១២% អនុវត្តបានមធ្យម
- បានពិនិត្យតាមដានការងារគ្រប់គ្រង និងផ្តល់ថវិកាអាហារូបករណ៍តាមគ្រឹះស្ថានមធ្យមសិក្សាតាមរយៈកម្មវិធីអាហារូបករណ៍បានចំនួន៣០សាលា ក្នុងនោះ ៦៥% អនុវត្តបានល្អ និង ៣៥% អនុវត្តបានល្អបង្គួរ
- បានពិនិត្យតាមដានការគ្រប់គ្រងស្ថិតិអប់រំ ការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍប្រចាំឆ្នាំ ការរៀបចំរបាយការណ៍សមិទ្ធកម្ម ចំនួន៣៧ សាលា
- បានពិនិត្យតាមដានការគ្រប់គ្រង និងអនុវត្តថវិកា ចំនួន ៧៦សាលា និងការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ចំនួន ១៤សាលា
- បានពិនិត្យតាមដានការគ្រប់គ្រងរដ្ឋបាល ចំនួន ៥សាលា ។

## ខ.ចង្កោមនៃភាពការសម្រេចបានសូចនាករអនុវិស័យការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស




គោលនយោបាយទី១ មានសូចនាករសរុប ១៨ ក្នុងនោះសម្រេចចំណុចដៅឆ្នាំសិក្សា២០១៧-២០១៨(បច្ចុប្បន្នភាពESP 2015-2017) មានសូចនាករ ៧ស្មើនឹង ៣៩% និងសូចនាករ ១១ ស្មើនឹង ៦១% (ពាក់ព័ន្ធនឹងការចូលរៀន និងគុណភាពអប់រំ) លទ្ធផលអាចទទួលយកបាន។ (ឧបសម្ព័ន្ធទី៤)

## គ.បញ្ហាប្រឈម៖

- កង្វះគ្រូឯកទេសតាមមុខវិជ្ជា ពិសេសមុខវិជ្ជាវិទ្យាសាស្ត្រ

- o នាយកបង្រៀនផង និងធ្វើការងាររដ្ឋបាលផង ចំពោះសាលារៀនអនុវិទ្យាល័យនៅតំបន់ជួបលំបាក
- o កង្វះអគារសិក្សា បណ្ណាល័យ បន្ទប់ពិសោធន៍នៅវិទ្យាល័យទាំង ១៤ និងផ្ទះសំណាក់គ្រូបង្រៀន នៅតាមសាលារៀនស្ថិតក្នុងតំបន់ជួបការលំបាក
- o សមត្ថភាពនាយកសាលាលើការអនុវត្តស្តង់ដាសាលាមធ្យមសិក្សា
- o សមត្ថភាពការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យារបស់គ្រូបង្រៀន
- o ការបោះបង់ការសិក្សារបស់សិស្សខ្ពស់នៅមធ្យមសិក្សាទុតិយភូមិ ។

ជារួម ការចូលរៀន និងការបញ្ចប់ការសិក្សារបស់សិស្ស នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ មានការកើនឡើង ទន្ទឹមនឹងការត្រួតថ្នាក់ និងបោះបង់ការសិក្សារបស់សិស្សក្នុងឆ្នាំសិក្សា២០១៦-២០១៧ ត្រូវបានកាត់បន្ថយជាមួយគ្នានិងអត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិកាន់តែប្រសើរជាងមុន ។ ដោយឡែកភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ការវាយតំលៃថ្នាក់ជាតិ)ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានការថយចុះជាងឆ្នាំសិក្សា២០១៥-២០១៦ ។ លទ្ធផលនេះបានបង្ហាញអំពីការបំពេញការងារនៅគ្រប់កម្រិតបានគែលម្អ ប៉ុន្តែត្រូវបន្តការយកចិត្តទុកដាក់ពង្រឹងគុណភាពគ្រូបង្រៀន និងការអនុវត្តម៉ោងបង្រៀនឱ្យបានពេញលេញ ។

## ២.៤ អនុវិស័យអប់រំក្រៅប្រព័ន្ធ

### ក.លទ្ធផលសម្រេចបាន

**ក.១ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា**

កម្មវិធីអប់រំក្រៅប្រព័ន្ធបានផ្តល់ឱកាសរៀនសូត្រ ដល់ជនគ្រប់រូបគ្រប់វ័យទាំងពីរភេទ ជាពិសេសកុមារ យុវជននៅក្រៅសាលានិងជនពេញវ័យជាអនក្ខរជនទទួលបានសេវាអប់រំ ដោយឥតបង់ថ្លៃ។

*ស្ថិតិថ្នាក់រៀន និងមណ្ឌលអានអប់រំក្រៅប្រព័ន្ធ*

| បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | ឆ្នាំសិក្សា ២០១៧-២០១៨ | កើន/ថយ (+/-) |
|---|---|---|---|
| ថ្នាក់រៀនអក្ខរកម្ម | 68 | 53 | -15 |

| | | | |
|---|---|---|---|
| បណ្ណាល័យ | 03 | 03 | -៎- |
| មណ្ឌលអាន | 09 | 09 | -៎- |
| កម្មវិធីចូលរៀនឡើងវិញ | 13 | 15 | +2 |
| មជ្ឈមណ្ឌលសិក្សាសហគមន៍ | 22 | 22 | -៎- |
| ថ្នាក់ជំនាញមុខរបរ | 59 | 59 | -៎- |
| ថ្នាក់សមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ | 08 | 08 | -៎- |
| ថ្នាក់បំពេញវិជ្ជាមធ្យមសិក្សាបឋមភូមិ | 01 | 01 | -៎- |
| ថ្នាក់បំពេញវិជ្ជាមធ្យមសិក្សាទុតិយភូមិ | 02 | 04 | +2 |

*ប្រភពទិន្នន័យ៖ ការិយាល័យអប់រំក្រៅប្រព័ន្ធ*

*ស្ថិតិគ្រូ និងអ្នកសិក្សាតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ*

| បរិយាយ | ឆ្នាំសិក្សា ២០១៥-២០១៦ | | ឆ្នាំសិក្សា ២០១៦-២០១៧ | | កើន/ថយ (+/-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| គ្រូអក្ខរកម្ម | 68 | 30 | 53 | 16 | -15 | -14 |
| អ្នកសិក្សាកម្មវិធីអក្ខរកម្ម | 1517 | 1090 | 1178 | 812 | -339 | -278 |
| សិស្សចូលរៀនឡើងវិញ | 218 | 96 | 247 | 94 | +29 | -02 |
| អ្នកសិក្សាជំនាញមុខរបរ | 741 | 395 | 791 | 429 | +50 | +34 |
| សិស្សសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ | 227 | 116 | 191 | 98 | -36 | -18 |
| សិស្សបំពេញវិជ្ជាមធ្យមសិក្សាបឋមភូមិ | 15 | 01 | 36 | 03 | +21 | +2 |
| សិស្សបំពេញវិជ្ជាមធ្យមសិក្សាទុតិយភូមិ | 179 | 64 | 289 | 87 | +110 | +23 |

*ប្រភពទិន្នន័យ៖ ការិយាល័យអប់រំក្រៅប្រព័ន្ធ*

*ស្ថិតិអ្នកសិក្សាបានបញ្ចប់ និងបញ្ជូនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ*

| បរិយាយ | ឆ្នាំសិក្សា ២០១៥-២០១៦ | | ឆ្នាំសិក្សា ២០១៦-២០១៧ | | កើន/ថយ (+/-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អ្នកសិក្សាកម្មវិធីអក្ខរកម្ម | 1375<br>89.5% | 1011<br>95.7% | 1153<br>94.8% | 812<br>97% | -222<br>+5.3% | -199<br>+1.3% |
| សិស្សចូលរៀនឡើងវិញ | 210 | 90 | 247 | 94 | +37 | -4 |
| សិស្សជំនាញមុខរបរបានបញ្ចប់ | 718 | 386 | 762 | 429 | +44 | +43 |
| សិស្សសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ | 227 | 116 | 157 | 81 | -70 | -35 |

| | | | | | | |
|---|---|---|---|---|---|---|
| សិស្សបំពេញវិជ្ជាមធ្យមសិក្សាបឋមភូមិបានប្រឡងជាប់ | 10 | 01 | 24 | 02 | +14 | +01 |
| សិស្សបំពេញវិជ្ជាមធ្យមសិក្សាទុតិយភូមិបានប្រឡងជាប់ | 116 | 43 | 194 | 58 | +78 | +15 |

*ប្រភពទិន្នន័យៈ ការិយាល័យអប់រំក្រៅប្រព័ន្ធ*

ចំនួនថ្នាក់អក្ខរកម្ម និងអ្នកសិក្សាក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានការថយចុះនិន្នាការនេះពាក់ព័ន្ធនឹងកត្តាមួយចំនួនដូចជាមិនមានបន្ថែមគ្រូអក្ខរកម្មមកពីមន្ទីរកិច្ចការនារីខេត្ត អនក្ខរជនអាយុលើស ៤៥ឆ្នាំ មិនស្ថិតក្នុងចំណុចដៅរបស់កម្មវិធី និងអនក្ខរជនមួយចំនួនផ្សេងទៀតត្រូវបានរំដោះជាបណ្ដើរៗជារៀងរាល់ឆ្នាំ ។

សិស្សបំប៉ននៅក្នុងកម្មវិធីចូលរៀនឡើងវិញ ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានការកើនឡើង និន្នាការនេះពាក់ព័ន្ធនឹងសិស្សបោះបង់ការសិក្សារយៈពេលច្រើនឆ្នាំ ហើយធ្លាប់បានផ្លាស់ប្ដូរទីលំនៅតាមឪពុកម្ដាយ ទៅកន្លែងឆ្ងាយៗមួយចំនួនបានវិលត្រឡប់មកកាន់លំនៅដ្ឋានដើមនិងចង់ចូលរៀនបន្ត មាតាបិតា និងអាណាព្យាបាលសិស្សភាគច្រើនមានការភ្ញាក់រឭកជំរុញ កូនឱ្យទៅរៀនបានគ្រប់ៗគ្នា ។

ចំនួនអ្នកសិក្សាជំនាញមុខរបរ ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានការកើនឡើង និន្នាការនេះពាក់ព័ន្ធនឹងកត្តាមួយចំនួនដូចជា នៅបណ្ដាតាមរោងចក្រ សហគ្រាស ទាមទារឱ្យកម្មករ កម្មការិនីដែលចូលបម្រើ ការងារ មានសមត្ថភាពស្របតាមតម្រូវទីផ្សាររបស់រោងចក្រ និងដើម្បីគុណភាព នៃសង្វាក់ផលិតផល ការផ្ដល់សេវាបណ្ដុះបណ្ដាលផ្នែកជំនាញមុខរបរនានានៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍នីមួយៗ បានអនុវត្តតាមផែនការ និងវត្ថុបំណងជាក់លាក់ ពិសេសកសាងធនធានមនុស្សស្របតាមតម្រូវការរបស់ប្រជាជន ឆ្លើយតបទៅនឹងទីផ្សារការងារក្នុងតំបន់បច្ចុប្បន្ន ។

ចំនួនសិស្សថ្នាក់ទី១២នៅសាលាបំពេញវិជ្ជាពាក់កណ្ដាលរៀបរយខេត្ត និងចំនួនសិស្សស្វែរិនបំពេញវិជ្ជាមានការកើនឡើង និន្នាការនេះពាក់ព័ន្ធនឹងកត្តាមួយចំនួនដូចជា មានការផ្សព្វផ្សាយព័ត៌មានស្ដីពីការចូលរៀនបានទូលំទូលាយដល់គ្រប់ក្រុងស្រុក ជ្រើសរើសគ្រូមកបង្រៀនមានសមត្ថភាព មនសិការវិជ្ជាជីវៈ បង្រៀនទៀងទាត់ និងទាន់ពេលវេលា។

## ក.២ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

### ក.២.១ ការអភិវឌ្ឍសមត្ថភាព

- បានបំប៉នសមត្ថភាពបង្រៀនជូនគ្រូអក្ខរកម្មកិច្ចសន្យាចំនួន១៩នាក់ស្រី១១នាក់
- បានបំប៉នសមត្ថភាពបង្រៀនគ្រូបង្រៀនក្នុងកម្មវិធីចូលរៀនឡើងវិញចំនួន១៥នាក់ ស្រី០១នាក់
- បានបំប៉នសមត្ថភាព ស្តីពីការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ជូនគណៈកម្មការគ្រប់គ្រងមសស ចំនួន២២ កន្លែង ដែលមានអ្នកចូលរួមចំនួន៦២ នាក់ស្រី ១២នាក់។

**ក.២.២ ការពិនិត្យតាមដាន**

- បានពិនិត្យតាមដានថ្នាក់អក្ខរកម្មចំនួន ៥៣ ថ្នាក់ ក្នុងនោះគ្រូបង្រៀនប្រមាណ ៧៥% បានធ្វើកិច្ចតែងការបង្រៀន គ្រូបង្រៀនតាមកម្មវិធីថ្នាក់ជាតិមានប្រមាណ ៧០% និង ៣០% តាមកម្មវិធីយូនីសេហ្វ
- បានពិនិត្យតាមដានថ្នាក់កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធចំនួន ០៨ ថ្នាក់ ក្នុងនោះ គ្រូបង្រៀនប្រមាណ ៧៥ % មានកិច្ចតែងការបង្រៀនត្រឹមត្រូវ សិស្សមករៀនទៀងទាត់បានចំនួន ៩០ % ហើយការចូលរៀន និងបញ្ចប់វគ្គសិក្សា ស្របតាមកម្មវិធីក្នុងប្រព័ន្ធ
- បានពិនិត្យតាមដានថ្នាក់កម្មវិធីចូលរៀនឡើងវិញចំនួន ១៥ ថ្នាក់ គ្រូបង្រៀនមាន កិច្ចតែងការបង្រៀនត្រឹមត្រូវ ១០០% និង សិស្សមករៀនទៀងទាត់បាន ចំនួន ៨៥ %
- បានពិនិត្យតាមដានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន ២២កន្លែង មានគ្រូជំនាញ ៥៩នាក់ ក្នុងនោះគ្រូជំនាញ ៨៦ % ប្រមូលអ្នកសិក្សាមុខជំនាញមកសិក្សា បានទៀងទាត់ ។

## ខ.ឧត្តមភាពនៃការសម្រេចបានសូចនាករអនុវិស័យការអប់រំក្រៅប្រព័ន្ធ




គោលនយោបាយទី១ មានសូចនាករសរុប ៥ ក្នុងនោះសម្រេចចំណុចដៅឆ្នាំសិក្សា២០១៧-២០១៨(បច្ចុប្បន្នភាពESP 2015-2017) មាន សូចនាករ ២ ស្មើនឹង ៤០% គឺសូចនាករ ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម និងចំនួនអ្នកសិក្សានៅមសសបានបញ្ចប់វគ្គបណ្តុះបណ្តាលសូចនាករ ១ ស្មើនឹង ២០% លទ្ធផលអាចទទួលយកបាន និង សូចនាករ២ ស្មើនឹង ៤០% មិនសម្រេចចំណុចដៅ ។

គោលនយោបាយទី២ មានសូចនាករសរុប ១ គឺអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធជាលទ្ធផលមិនទាន់អនុវត្ត។(ឧបសម្ព័ន្ធទី៨)

**គ.បញ្ហាប្រឈម៖**

- ការផ្តល់សម្ភារដំណើរការថ្នាក់អក្ខរកម្ម មានភាពយឺតយ៉ាវ
- ការចូលរួមក្រុមមុខសញ្ញាឱ្យចូលរៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ
- កង្វះឥណទាន សម្រាប់បង្កើតមុខរបរក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញនៅ មជ្ឈមណ្ឌលសិក្សាសហគមន៍
- ការចូលរួមរបស់គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងសមត្ថភាពរបស់មន្ត្រីទទួលបន្ទុក ការងារអប់រំក្រៅប្រព័ន្ធ ក្រុងស្រុក ឃុំសង្កាត់ ។

ជារួមក្នុងឆ្នាំសិក្សា២០១៦-២០១៧កន្លងទៅនេះ ភាគរយសិស្សអក្ខរកម្មបានបញ្ចប់មានការកើនឡើង ជាមួយគ្នានេះ ចំនួនសិស្សបានសិក្សា និងបញ្ចប់ជំនាញនៅមជ្ឈមណ្ឌលសិក្សាសហគមន៍ក៏មានការកើនផងដែរ មួយវិញទៀត ចំនួនកុមារក្នុងកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធមានការថយចុះ ដែលបានបង្ហាញពីការផ្តល់សេវាអប់រំក្នុងប្រព័ន្ធ តាមរយៈការសាងសង់អគារសិក្សា ការបង្កើតសាលារៀនបន្ថែម ជាដើម ។

## ២.៥.អនុវិស័យការអភិវឌ្ឍយុវជន

### ក.លទ្ធផលសម្រេចបាន

**ក.១ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា**

ចំនួនក្រុមប្រឹក្សាកុមារ-យុវជន និងកុមារ-យុវជន ពល្អ

| បរិយាយ | 2016 | 2017 | (+/-) |
|---|---|---|---|
| ចំនួនក្រុមប្រឹក្សាកុមារ | 335 | 335 | -៥- |
| ចំនួនក្រុមប្រឹក្សាយុវជន | 15 | 15 | -៥- |
| ចំនួនកុមារ ពល្អ | 36149 | 37186 | +1037 |
| ចំនួនយុវជន ពល្អ | 1824 | 2092 | +268 |

*ប្រភពទិន្នន័យ៖ ការិយាល័យយុវជន*

ចំនួនក្រុមប្រឹក្សាកុមារ និងយុវជន មិនមានការប្រែប្រួល ក្នុងឆ្នាំសិក្សា២០១៦-២០១៧ កន្លងទៅនេះ ដោយឡែក ចំនួនកុមារ ពល្អ និងយុវជនពល្អ

មានការកើនឡើងគួរឱ្យកត់សម្គាល់ ទិន្នាការនេះ ដោយសារ មានការលើកទឹកចិត្ត ផ្តល់រង្វាន់ប័ណ្ណសរសើរជូនបុគ្គល និងអង្គភាពមានស្នាដៃ។

រូបភាពទី១៥ ៖ %សិស្ស ថ្នាក់ទី៤-៩ ចូលរួមក្នុងក្រុមប្រឹក្សាកុមារ និងសិស្សថ្នាក់ទី១០-១២ ចូលរួមក្នុងប្រឹក្សាយុវជន




*ប្រភពទិន្នន័យ៖ ការិយាល័យយុវជន*

ក្នុងឆ្នាំសិក្សា២០១៦-២០១៧ សិស្សថ្នាក់ទី៤-៩ បានចូលរួមក្នុងក្រុមប្រឹក្សាកុមារ ១០០% និងសិស្សថ្នាក់ទី១០-១២ បានចូលរួមក្នុងក្រុមប្រឹក្សាយុវជន ១០០% លទ្ធផលនេះ បើធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៥-២០១៧ សម្រេចចំណុចដៅ ។

រូបភាពទី១៦ ៖ វឌ្ឍនភាពភាគរយក្រុមប្រឹក្សាកុមារ-យុវជន មានដំណើរការល្អ




*ប្រភពទិន្នន័យ៖ ការិយាល័យយុវជន*

ភាគរយក្រុមប្រឹក្សាកុមារ មានដំណើរការល្អ ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានការកើនឡើង បើធៀបនឹងឆ្នាំសិក្សា២០១៥-២០១៦ និងធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៥-២០១៧ ៥២% មិនសម្រេចចំណុចដៅនៅឡើយ ដោយឡែក ភាគរយក្រុមប្រឹក្សាយុវជនមានដំណើរការល្អ ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ និងសម្រេចចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៥-២០១៧ និន្នាការដោយសារ ការអនុវត្តកម្មវិធីកំណែទម្រង់ការងារយុវជន នៅកម្រិតសាលារៀន ។

*រូបភាពទី១៧៖ ចំនួនយុវជនបានបណ្តុះបណ្តាលជំនាញខ្លី ការងារស្ម័គ្រចិត្ត យុវជនបង្កើតការងារ និងធ្វើសកម្មភាពស្ម័គ្រចិត្ត*




*ប្រភពទិន្នន័យ៖ ការិយាល័យយុវជន*

ចំនួនយុវជនបានបណ្តុះបណ្តាលជំនាញខ្លី (សំអាងកាយ និងកុំព្យូទ័រ) ក្នុងឆ្នាំ២០១៧ និងចំនួនយុវជនបានបង្កើតការងារដោយខ្លួនឯង មានការកើនឡើង មូលហេតុថវិកាអនុវត្តបានផ្ទេរពីក្រសួងអប់រំ យុវជន និងកីឡាមានការកើនឡើង បើធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៥-២០១៧ សម្រេចចំណុចដៅ។ ចំពោះចំនួនយុវជនបានបណ្តុះបណ្តាលការងារស្ម័គ្រ មានការថយចុះ ដោយសារ ថវិកាគាំទ្រ មិនឆ្លើយតបនឹងកម្មវិធីគ្រោងទុក ។ បើធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៥-២០១៧ មិនសម្រេចចំណុចដៅ។

*រូបភាពទី១៨៖ វឌ្ឍនភាពការពង្រីកកាយរឹទ្ធ និងកាយរឹទ្ធប្អូន*




*ប្រភពទិន្នន័យ៖ ការិយាល័យយុវជន*

ចំនួនកាយរឹទ្ធិ និងកាយរឹទ្ធិប្អូន បានពង្រីកក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានការថយចុះ បើធៀបនឹងឆ្នាំសិក្សា២០១៥-២០១៦ ដោយសារ ការផ្តល់គ្រឿងឥស្សរិយយសមិនឆ្លើយតបនឹងការគ្រោងទុក
ប៉ុន្តែលទ្ធផលការពង្រីកកាយរឹទ្ធិ
ធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៥-២០១៧ បានសម្រេចចំណុចដៅ ដោយឡែកការពង្រីកកាយរឹទ្ធិប្អូន នៅមិនទាន់សម្រេចចំណុចដៅនៅឡើយ។

### ក.២ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

#### ក.២.១ការអភិវឌ្ឍសមត្ថភាពមន្ត្រី

មិនមានថវិកាសម្រាប់អនុវត្ត ។

**ក.២.២ការពិនិត្យតាមដាន ៖**

- បានពិនិត្យតាមដានការងារក្រុមប្រឹក្សាកុមារ និងយុវជនតាមសាលារៀនចំនួន ៣១ សាលារៀន ក្នុងនោះ សាលាបឋមសិក្សា ២៩ និងមធ្យមសិក្សា ២
- បានពិនិត្យតាមដានសកម្មភាព របស់យុវជនស្ម័គ្រចិត្ត ចំនួន ៣០នាក់
- បានពិនិត្យតាមដានកែលម្អ និងបំផុសការងារស្ម័គ្រចិត្តដល់យុវជនក្នុង និងក្រៅសាលារៀន ចំនួន ៩៥នាក់ នៅតាមគ្រឹះស្ថានសិក្សាចំនួន ៦សាលា និងសហគមន៍ចំនួន ២១ ឃុំ/សង្កាត់។

## ខ.វឌ្ឍនភាពនៃការសម្រេចបានសូចនាករអនុវិស័យ ការអភិវឌ្ឍយុវជន




គោលនយោបាយទី១ មានសូចនាករសរុប ៩ ក្នុងនោះសម្រេចចំណុចដៅឆ្នាំសិក្សា២០១៧-២០១៨(បច្ចុប្បន្នភាពESP 2015-2017) មានសូចនាករ ៦ ស្មើនឹង៦៦% និង សូចនាករ៣ស្មើនឹង ៣៤% មិនសម្រេចចំណុចដៅ។ (ឧបសម្ព័ន្ធទី៨)

**គ.បញ្ហាប្រឈម៖**

- កង្វះហេដ្ឋារចនាសម្ព័ន្ធមជ្ឈមណ្ឌលយុវជន (អគារមជ្ឈមណ្ឌលមានសភាពចាស់ទ្រុឌទ្រោម)
- កង្វះឯកសារគាំទ្រកិច្ចដំណើរក្រុមប្រឹក្សាកុមារ និងយុវជននិងកុំព្យូទ័រសម្រាប់បណ្តុះបណ្តាលយុវជន
- កង្វះថវិកាគាំទ្រការងារបណ្តុះបណ្តាលជំនាញដល់យុវជនបាត់បង់ឱកាស ពង្រឹងសមត្ថភាព អ្នកគ្រប់គ្រង ដឹកនាំ និងដំណើរការក្រុមប្រឹក្សាកុមារ និងយុវជន ការងារកាយរឹទ្ធិជាតិកម្ពុជា ការងារយុវជនស្ម័គ្រចិត្ត និងការងារពិនិត្យតាមដាន។

ជារួមក្នុងឆ្នាំសិក្សា២០១៦-២០១៧ កន្លងមកនេះ ចំនួនកុមារ-យុវជន ៣ល្អ និងភាគរយក្រុមប្រឹក្សាកុមារ-យុវជនមានដំណើរការល្អ មានការកើនឡើងគួរឱ្យកត់សម្គាល់ និងរក្សាបានសិស្សថ្នាក់ទី៤-៩ និងសិស្សថ្នាក់ទី១០-១២ ចូលរួមក្នុងក្រុមប្រឹក្សាកុមារ-យុវជន១០០% ។ ប៉ុន្តែចំនួនយុវជនបានបណ្តុះបណ្តាលការងារស្ម័គ្រចិត្តមានការថយចុះ និងយុវជនអនុវត្តការងារស្ម័គ្រចិត្តនៅមានចំនួនតិចតួចនៅឡើយ ដែលត្រូវយកចិត្តទុកដាក់លើកទឹកចិត្ត តាមរយៈ បន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញខ្លី ជូនយុវជនទាំងក្នុង និងក្រៅសាលា ។

## ២.៦.អនុវិស័យការអប់រំកាយ និងកីឡា

### ក.លទ្ធផលសម្រេចបាន

#### ក.១ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

រូបភាពទី១៩ ៖វឌ្ឍនភាពការអនុវត្តសកម្មភាពអប់រំកាយ និងកីឡា (២ម៉ោង/១សប្តាហ៍) តាមសាលារៀន




*ប្រភពទិន្នន័យ៖ ការិយាល័យកីឡា*

ចំនួនសាលារៀនបានអនុវត្តកម្មវិធីអប់រំកាយ និងកីឡា ២ម៉ោងក្នុង១សប្តាហ៍ ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មានការកើនឡើង ៣៩សាលា បើធៀបនឹងឆ្នាំសិក្សា២០១៥-២០១៦ និន្នាការនេះដោយសារមានការចុះជួយការងារបច្ចេកទេស តាមសាលារៀន ។ លទ្ធផលសម្រេចបាន ១០៦សាលា បើធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៥-២០១៦ ១១០សាលា លទ្ធផលកៀកចំណុចដៅ ។

*រូបភាពទី២០៖ ចំនួនគ្រឹះស្ថានមធ្យមសិក្សាមានទីលានកីឡា*




*ប្រភពទិន្នន័យ៖ ការិយាល័យកីឡា*

ចំនួនទីលានកីឡានៅតាមគ្រឹះស្ថានសិក្សាមធ្យមសិក្សាក្នុងឆ្នាំសិក្សា២០១៦-២០១៧មិនមានការប្រែប្រួល បើធៀបនឹងឆ្នាំសិក្សា២០១៥-២០១៦ មូលហេតុមិនមានថវិកាសម្រាប់សាងសង់ ។ លទ្ធផលសម្រេចបាន ទីលានបាល់ទាត់៣៩កន្លែង

ទីលានបាល់បោះ ១៤កន្លែង និងទីលានបាល់ទះ ៦៦កន្លែង បើធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាព ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៥-២០១៦ ១១០សាលា លទ្ធផលកៀកចំណុចដៅ ។

*រូបភាពទី២១៖ ចំនួនមេដាយក្នុងការប្រកួតកីឡាថ្នាក់ជាតិ*




*ប្រភពទិន្នន័យ៖ ការិយាល័យកីឡា*

ក្នុងឆ្នាំសិក្សា២០១៦-២០១៧ ចំនួនមេដាយការប្រកួតកីឡាសិស្សបឋមសិក្សាទទួលបាន ១គ្រឿង ចំនួនមេដាយការប្រកួតកីឡាសិស្សមធ្យមសិក្សាទទួលបាន ៣គ្រឿង បើធៀបនឹងឆ្នាំសិក្សា២០១៥-២០១៦ ថយចុះ ៤គ្រឿង មូលហេតុដោយសារ មានការផ្លាស់ប្តូរកាលបរិច្ឆេទនៃការប្រកួត និងវិញ្ញាសានៃការប្រកួត បើធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៥-២០១៧ មិនសម្រេចចំណុចដៅនៅឡើយ ។ ដោយឡែកចំនួនមេដាយការប្រកួតកីឡាថ្នាក់ជាតិ (មហាជន)ទទួលបាន ៤៤គ្រឿង ដោយសារ មានកើនឡើងចំនួនក្រុមកីឡាករ និងវិញ្ញាសាប្រកួត បើធៀបនឹងចំណុចដៅនៃឯកសារការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៥-២០១៧ សម្រេចចំណុចដៅ ។

## ក.២ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

### ក.២.១ការអភិវឌ្ឍសមត្ថភាពមន្ត្រី

មិនមានថវិកាសម្រាប់អនុវត្ត ។

**ក.២.២ការពិនិត្យតាមដាន ៖**

- បានពិនិត្យតាមដានការអនុវត្តសកម្មភាពអប់រំកាយនិងកីឡា នៅតាមសាលារៀនចំនួន១៤៣ សាលា ក្នុងនោះសាលារៀនបឋមសិក្សា ចំនួន ១១១ សាលា និង មធ្យមសិក្សា ចំនួន ៣២ សាលា ។

## ខ.វឌ្ឍនភាពនៃការសម្រេចបានសូចនាករអនុវិស័យ ការអប់រំកាយ និងកីឡា




គោលនយោបាយទី១ មានសូចនាករសរុប ៧ ក្នុងនោះសម្រេចចំណុចដៅឆ្នាំសិក្សា២០១៧-២០១៨(បច្ចុប្បន្នភាពESP 2015-2017) មាន សូចនាករ ១ ស្មើនឹង ១៤% លទ្ធផល សូចនាករ ៤ស្មើនឹង ៥៨% លទ្ធផលអាចទទួលយកបាន និង សូចនាករ ២ ស្មើនឹង ២៨% មិនសម្រេចចំណុចដៅ ។ (ឧបសម្ព័ន្ធទី៤)

**គ.បញ្ហាប្រឈម**

- កង្វះហេដ្ឋារចនាសម្ព័ន្ធទីលានកីឡាតាមគ្រឹះស្ថានសិក្សា
- កង្វះឯកសារមេរៀនអប់រំកាយ សម្រាប់គ្រឹះស្ថានមធ្យមសិក្សា
- កង្វះគ្រូឯកទេសអប់រំកាយ និងកីឡា និងសមត្ថភាពនៅមានកម្រិត
- កង្វះថវិកាសម្រាប់ការហ្វឹកហាត់ និងប្រកួតនៅតាមគ្រឹះស្ថានសិក្សា និងក្រុងស្រុក
- កង្វះថវិកាសម្រាប់ពិនិត្យតាមដាន និងបើកវគ្គបំប៉នអប់រំកាយ និងកីឡា ។

ជារួមក្នុងឆ្នាំសិក្សា២០១៦-២០១៧ ចំនួនសាលារៀន (បឋមសិក្សា និងមធ្យមសិក្សា) អនុវត្តកម្មវិធីអប់រំកាយ និងកីឡា ២ម៉ោងក្នុង១សប្តាហ៍ មានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយឡែក ចំនួនទីលានកីឡានៅតាមសាលារៀនមធ្យមសិក្សា មិនមានការកើនឡើង ជាលទ្ធផលប្រចាំឆ្នាំសិក្សា

ចំនួនមេដាយនៃការប្រកួតកីឡាសិស្សមធ្យមសិក្សាមានការថយចុះពី ៧គ្រឿង មកត្រឹម ៣គ្រឿងប៉ុណ្ណោះ ។ លទ្ធផលខាងលើបានបង្ហាញពីកម្រិតនៃការបំពេញការងារទាមទារឱ្យមានការកែលម្អតាមរយៈការកែលម្អទីលានកីឡាតាមសាលារៀន ការផ្ដល់សម្ភារកីឡាដល់សាលារៀនសម្រាប់ហ្វឹកហាត់ និង ការបំប៉នសមត្ថភាពគ្រូបង្រៀនអប់រំកាយ និងកីឡា ។

## III.ទិសដៅការងារ ឆ្នាំសិក្សា២០១៧-២០១៨

### ១.ទិសដៅតាមអនុវិស័យ

ផ្អែកលើលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១៦-២០១៧មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ឆ្នាំង កំណត់ទិសដៅសម្រាប់អនុវត្តក្នុងឆ្នាំសិក្សា២០១៧-២០១៨ ដើម្បីឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្ត ប្រកបដោយការទទួលខុសត្រូវក្នុងការអនុវត្តទិសដៅអាទិភាពឆ្នាំ២០១៨-២០២០
និងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ ដូចតទៅ ៖

#### ១.១.អនុវិស័យការអប់រំកុមារតូច

- ប្រមូលកុមារចូលរៀនអាយុ ៥ឆ្នាំ ក្នុងកម្មវិធីអប់រំកុមារតូចគ្រប់រូបភាពឲ្យបាន៧០%
- ប្រមូលកុមារចូលរៀនអាយុ ៤ឆ្នាំ ក្នុងកម្មវិធីអប់រំកុមារតូចគ្រប់រូបភាពឲ្យបាន៤៥%
- ប្រមូលកុមារចូលរៀនអាយុ ៣ឆ្នាំ ក្នុងកម្មវិធីអប់រំកុមារតូចគ្រប់រូបភាពឲ្យបាន២៤%
- បង្កើនភាគរយសេវាអប់រំកុមារតូចដែលបានអនុវត្តតេស្តទៀងទាត់ដើម្បីវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំជាទៀងទាត់ឲ្យបាន៩០%
- បង្កើនភាគរយកុមារក្នុងសេវាគាំពារ និងអភិវឌ្ឍកុមារតូចដែលមានស្ថានភាពអាហារូត្ថម្ភឲ្យបាន៦០%។
- បង្កើនភាគរយកុមារនៅតាមសាលាមត្តេយ្យទទួលបានថ្នាំទំលាក់ព្រូនឲ្យបាន ៩៦% ។

#### ១.២ អនុវិស័យការអប់រំបឋមសិក្សា

- បង្កើនភាគរយសាលាកុមារមេត្រី កម្រិតមធ្យមនិងកម្រិតអភិវឌ្ឍ៧០%
- បង្កើនអត្រាពិតចូលរៀនថ្មី ៩៨% ស្រី ៩៨%
- បង្កើនអត្រាពិតនៃការសិក្សា ៩៧% ស្រី ៩៨%
- កាត់បន្ថយអត្រាបោះបង់ការសិក្សា ២% ស្រី ២%
- កាត់បន្ថយអត្រាត្រួត ថ្នាក់ ៥% ស្រី ៤%
- បង្កើនអត្រាបញ្ចប់ការសិក្សា ៩០% ស្រី ៩៣%
- បង្កើនភាគរយសិស្សថ្នាក់ទី ១ ដែលបានឆ្លងកាត់មត្តេយ្យសិក្សា ៧២%
- បង្កើនអត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅ មធ្យមសិក្សាបឋមភូមិ ៩០%ស្រី ៩៤%
- បង្កើនភាគរយសាលាបឋមសិក្សាមាន

-បង្គន់អនាម័យ និងទឹកស្អាត៩៨%

-កន្លែងសម្អាតដៃ ៧០% ។

### ១.៣ អនុវិស័យមធ្យមសិក្សា និងអប់រំបច្ចេកទេស

- កាត់បន្ថយអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ១១% ស្រី១០%
- កាត់បន្ថយអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ១៧%ស្រី១៥%
- បង្កើនអត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ៦២%ស្រី ៦៨%
- បង្កើនអត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ៣១%ស្រី ៣១%
- បង្កើនអត្រាឆ្លងភូមិសិក្សាពីបឋមភូមិទៅទុតិយភូមិ៧៧%ស្រី៧៩%
- បង្កើនអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ៥២% ស្រី ៥៩%
- បង្កើនភាគរយសាលាមធ្យមសិក្សាបឋមភូមិមានបង្គន់អនាម័យ៩៨%
- បង្កើនចំនួនសិស្សក្នុងការអប់រំបច្ចេកទេស២៧០នាក់ស្រី ១១០នាក់
- ចំនួនសិស្សពូកែប្រឡងថ្នាក់ជាតិទទួលបានជ័យលាភី ៦នាក់ ស្រី៣នាក់។

### ១.៤ អនុវិស័យអប់រំក្រៅប្រព័ន្ធ

- បង្កើនចំនួនលទ្ធផលរំដោះគ្រោះមិនចេះអក្សរចំនួន ១០៣៨នាក់ស្រី ៦២០នាក់ ចំនួនសិស្សអក្ខរកម្ម៦២០នាក់ស្រី ៥៧៦នាក់ ស្មើនឹង ៩៣%
- រក្សាកុមាររៀននៅកម្មវិធីសមមូលបឋមសិក្សាឆ្នាំទី១ ឱ្យបន្តការសិក្សានៅឆ្នាំទី២ ចំនួន ០៧ ថ្នាក់សិស្សសរុប ២០៥នាក់ស្រី ១១១នាក់ និងបញ្ជូនសិស្សរៀននៅ ឆ្នាំទី ២ ទៅសាលាបឋមសិក្សាចំនួន ០១ ថ្នាក់ មានសិស្សសរុប ២០នាក់ស្រី ១៩នាក់
- ប្រមូលសិស្សក្នុងកម្មវិធីចូលរៀនឡើងវិញឱ្យបាន ១៧ថ្នាក់មានសិស្សចូលរៀនសរុប ២៨៩នាក់ ស្រី១៤៥នាក់ និងបញ្ជូនទៅសាលាបឋមសិក្សាបាន៩៧%
- រក្សាឱ្យបាននូវចំនួនអ្នកចូលរៀនកម្មវិធីបង្កើនប្រាក់ចំណូលចំនួន ៨៤០ នាក់ ស្រី ៥៨៨នាក់ ហើយបញ្ចប់កម្មវិធីចំនួន ៧៩៨ នាក់ ស្រី ៥៥៩នាក់ និងអាចរកការងារធ្វើបានប្រមាណ៣៥%
- រក្សាឱ្យបាននូវចំនួនអ្នកចូលរៀននៅសាលាបំពេញវិជ្ជាថ្នាក់ទី៩ចំនួន២៨នាក់ ស្រី០១នាក់ និងថ្នាក់ទី១២ ចំនួន ១៨៥ នាក់ ស្រី ៤៥នាក់
- រៀបចំឱ្យមានមន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ គ្រប់ឃុំ ។

### ១.៥ អនុវិស័យការអភិវឌ្ឍយុវជន

- យុវជនត្រូវបានការបណ្តុះបណ្តាលជំនាញខ្លីៗ ចំនួន៤៥នាក់

- យុវជនក្នុង និងក្រៅសាលា ត្រូវបានអនុវត្តសកម្មភាពការងារស្ម័គ្រចិត្ត ១១០នាក់
- សិស្សថ្នាក់ទី ៤-៩ ត្រូវបានចូលរួមក្នុងក្រុមប្រឹក្សាកុមារ១០០%
- សិស្សថ្នាក់ទី ១០-១២ ត្រូវបានចូលរួមក្នុងក្រុមប្រឹក្សាយុវជន១០០%
- ក្រុមប្រឹក្សាកុមារមានដំណើរការសកម្មភាព ៥២%
- ក្រុមប្រឹក្សាយុវជន មានដំណើរការសកម្មភាព ៨០%
- សមាជិកកាយរឹទ្ធិជាតិកម្ពុ ជាបានពង្រីកគ្រប់វិទ្យាល័យចំនួន៣០០នាក់និងកាយរឹទ្ធិប្អូនចំនួន៥០០នាក់
- យុវជនដែលទទួលបានការបណ្តុះបណ្តាលភាពការយល់ដឹងសហគ្រិនភាព

  ៣០ នាក់។

## ១.៦ អនុវិស័យការអភិវឌ្ឍការអប់រំកាយ និងកីឡា

- ចំនួនសាលារៀនត្រូវបានអនុវត្តសកម្មភាពអប់រំកាយនិងកីឡា២ម៉ោងក្នុង១ សប្តាហ៍ មានចំនួន១២៥ សាលា ។
- ក្រុមកីឡាសិស្សបឋមសិក្សាចូលរួមប្រកួតជ្រើសរើសជើងឯកថ្នាក់ខេត្តមានចំនួន៤៣ក្រុម។
- ក្រុមកីឡាសិស្សមធ្យមសិក្សាចូលរួមប្រកួតជ្រើសរើសជើងឯកថ្នាក់ខេត្ត មានចំនួន ៥០ ក្រុម ។
- ក្រុមកីឡាមហាជនចូលរួមប្រកួតជ្រើសរើសជើងឯកថ្នាក់ខេត្តមានចំនួន៨ប្រភេទកីឡាគឺបាល់ទាត់បាល់ទះបាល់បោះអត្តពលកម្មប៉េតង់វាយសីល្បុក្កតោ និងចំបាប់។
- ចំនួនមេដាយក្នុងការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិ ដណ្តើមបានចំនួន ២ គ្រឿង ។
- ចំនួនមេដាយក្នុងការប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិដណ្តើមបានចំនួន៥គ្រឿង។
- ក្រុមកីឡាបាល់ទាត់មហាជនចូលរួមប្រកួតពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនលើកទី១១មានចំនួន១ក្រុម។
- ក្រុមកីឡាបាល់ទាត់នារីអាយុក្រោម ១៤ឆ្នាំ ចូលរួមប្រកួតជម្រើសជើងឯកឆ្នាំ២០១៨ មានចំនួន ១ក្រុម និងអាយុក្រោម ១៦ឆ្នាំ ១ក្រុម។

- ➢ សាលារៀនត្រូវបានចុះតាមដានត្រួតពិនិត្យ ការអនុវត្តកម្មវិធីអប់រំកាយនិងកីឡា មានចំនួន ១៦០សាលា ។
- ➢ ទំនាក់ទំនងសប្បុរសជនអង្គការក្រៅរដ្ឋាភិបាលពីគ្រប់អ្នកពាក់ព័ន្ធជួយគាំទ្រ សាងសង់ទីលានកីឡា និង ឧបត្ថម្ភសម្ភារ ថវិកា ដំណើរការហ្វឹកហាត់ និងការប្រកួតតាមប្រភេទកីឡា ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។

## ២.បញ្ហាប្រឈមនិងទិសដៅរបស់ការិយាល័យគាំទ្រ/ឆ្លងអនុវិស័យ

ការិយាល័យផែនការ និងគ្រប់គ្រងជំនួយ

បញ្ហាប្រឈម៖

- ការបំពេញទិន្នន័យស្ថិតិអប់រំតាមកាលកំណត់ នៅមិនទាន់ឆ្លើយតបនឹងចរិកនៃស្ថិតិ
- សមត្ថភាពមន្ត្រីជំនាញក្នុងការរៀបចំផែនការអប់រំគ្រប់ប្រភេទ និងរបាយការណ៍វិភាគលទ្ធផល នៅមិនទាន់ឆ្លើយតបនឹងតម្រូវការការងារ
- សមត្ថភាពរបស់នាយកសាលារៀន អំពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន (SDSP) និងផែនការប្រតិបត្តិប្រចាំឆ្នាំ (SAOP) ។

ទិសដៅ៖

- ➢ បន្តបំប៉នសមត្ថភាពនាយក នាយិកាសាលារៀនគោលដៅ អំពីការបំពេញតារាងជំរឿនស្ថិតិសាលារៀនសាធារណ: តារាងសម្រង់ពិន្ទុសិស្សតាមមុខវិជ្ជា
- ➢ ដាក់ឱ្យអនុវត្តការរៀបចំរបាយការណ៍សមិទ្ធកម្មនៅកម្រិតសាលារៀន តាមទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា
- ➢ ពង្រឹងយន្តការដំណើរការក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំខេត្ត (JTWG)
- ➢ គាំទ្របច្ចេកទេសការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៩ របាយការណ៍សមិទ្ធកម្មនៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក
- ➢ គាំទ្របច្ចេកទេសការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនឆ្នាំ២០១៩-២០២១ និងផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៩ នៅកម្រិតសាលារៀន
- ➢ បន្តពង្រឹងគុណភាពផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៩ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត
- ➢ រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ (ESP) ។

ការិយាល័យបុគ្គលិក និងបណ្ដុះបណ្ដាល

**បញ្ហាប្រឈម៖**

- កង្វះថវិកាពិនិត្យតាមដាន ការងារការគ្រប់គ្រងបុគ្គលិក
- របាយគ្រូបង្រៀននៅតាមសាលារៀន
- ការពង្រាយគ្រូបង្រៀនមិនទាន់ឆ្លើយតបនឹងចំណុចដៅប្រចាំឆ្នាំ ។

**ទិសដៅ៖**

- ➢ បន្តដោះស្រាយ និងពង្រឹងប្រសិទ្ធភាព គុណភាពអប់រំ
- ➢ បែងចែកគ្រូបង្រៀនចេញថ្មីទៅដល់សាលារៀនខ្វះគ្រូ
- ➢ បន្តស្នើសុំតែងតាំងមន្ត្រីគ្រប់គ្រង / នាយក /រង /នាយិកា /រងសាលារៀន
- ➢ បើកផ្តល់ប្រាក់ឧបត្ថម្ភជីវភាពគ្រូនៅតំបន់ជួបការលំបាក ឱ្យបានទាន់ពេលវេលា
- ➢ ធ្វើបច្ចុប្បន្នភាពព័ត៌មានមន្ត្រីអប់រំជាប្រចាំ ក្នុងប្រព័ន្ធ HRMIS
- ➢ រៀបចំឯកសារបៀវត្សជាប្រចាំខែ សម្រាប់បុគ្គលិកអប់រំទូទាំងខេត្ត
- ➢ រៀបចំសំណើសុំតម្លើងកាំប្រាក់ និងតែងតាំងស៊ប់មន្ត្រីអប់រំប្រចាំឆ្នាំ ។

ការិយាល័យគណនេយ្យ សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ

**បញ្ហាប្រឈម៖**

- សមត្ថភាពរបស់ក្រុមការងារ/គណៈកម្មការក្នុងការគ្រប់គ្រង ប្រើប្រាស់ថវិកា និងគ្រប់គ្រងសម្ភារ តាមសាលារៀនមួយចំនួន
- ការរៀបចំរបាយការណ៍ទូទាត់មានភាពយឺតយ៉ាវ
- កង្វះថវិកាសម្រាប់បំប៉នសមត្ថភាពក្នុងចុះបញ្ជីសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ
- ការដោះស្រាយដីមានទំនាស់ មានភាពយឺតយ៉ាវ ។

**ទិសដៅ៖**

- ➢ អនុវត្តថវិកាប្រចាំឆ្នាំ២០១៨ ឱ្យបាន ៩៨.១%
- ➢ បន្តផ្សព្វផ្សាយ អំពីគោលការណ៍ណែនាំ នីតិវិធីហិរញ្ញវត្ថុ ដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក និងសាលារៀន ឱ្យបានទូលំទូលាយ និងទាន់ពេលវេលា។
- ➢ រៀបចំនិងផ្សព្វផ្សាយ សៀវភៅផែនការថវិកាប្រចាំឆ្នាំ២០១៨ ឱ្យបានទាន់ពេលវេលា
- ➢ ពិនិត្យតាមដាន និងកែលម្អ ការអនុវត្តថវិកា ការគ្រប់គ្រងសម្ភារ ទ្រព្យសម្បត្តិរដ្ឋ តាមសាលារៀន
- ➢ បន្តទំនាក់ទំនងជាមួយក្រសួងអប់រំ យុវជន និងកីឡា អង្គភាពពាក់ព័ន្ធ ពន្លឿនការដោះស្រាយទំនាស់ដីធ្លីតាមសាលារៀន។

➢ សហការជាមួយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសុរិយោដីខេត្តកំពង់ឆ្នាំងក្នុងការចុះវាស់វែងដី ធ្វើប្លង់កម្មសិទ្ធិ អង្គភាព ១៣៩ ទីតាំង ។

## ការិយាល័យអធិការកិច្ច

**បញ្ហាប្រឈម៖**

- នាយកសាលាមិនមានផែនការអធិការកិច្ច និងមិនបានចុះអធិការកិច្ចមើលការបង្រៀនរបស់គ្រូ
- ការបង្រៀនមិនទាន់ស្របតាមតម្រូវការរបស់សិស្សនៅឡើយ សិស្សរៀនតែទ្រឹស្តី ខ្វះសម្ភារ និងបន្ទប់ពិសោធន៍ គ្រូបង្រៀនមិនផលិត និងប្រើប្រាស់សម្ភារឧបទេស
- នៅមានសាលារៀនដែលមានសម្ភារពិសោធន៍ហើយតែនាយកចាក់សោរទុកក្នុងទូមិនប្រើប្រាស់
- សាលារៀនដែលបានធ្វើស្វ័យវាយតម្លៃមានចំនួនតិចតួច ។

**ទិសដៅ៖**

➢ ធ្វើអធិការកិច្ចសាលារៀនបឋមសិក្សាចំនួន ៣៣ មធ្យមសិក្សាចំនួន ១៦ និងសាលារៀនឯកជនចំនួន ១សាលា

➢ ធ្វើតេស្តភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ទី៣ ចំនួន ២០សាលា ។

## ការិយាល័យរដ្ឋបាល

**បញ្ហាប្រឈម៖**

- សមត្ថភាពមន្ត្រីរដ្ឋបាលរបស់មន្ទីរ ការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក និងសាលារៀន លើការគ្រប់គ្រងរដ្ឋបាលអប់រំនៅមានកម្រិត
- ការងារលើកសំណើផ្តល់គ្រឿងឥស្សរិយយសរបស់ការិយាល័យអប់រំ យុវជន និងកីឡាមួយចំនួនមិនទាន់ពេលវេលា ។

**ទិសដៅ៖**

➢ ចងក្រង និងទុកដាក់ឯកសារ លិខិតស្នាម ឱ្យមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព៩០%

➢ បុគ្គលិក និងអង្គភាពអប់រំ ១០% ក្នុង១ឆ្នាំ ត្រូវបានវាយតម្លៃ និងលើកសំណើផ្តល់គ្រឿងឥស្សរិយយសការងារ

➢ ចំនួនបុគ្គលិកអប់រំត្រូវបានចូលរួមសន្និបាតអប់រំ ថ្នាក់ខេត្ត ២៦២នាក់

- ត្រួតពិនិត្យតាមដាន និងកែលម្អការងារគ្រប់គ្រងរដ្ឋបាលនៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកឱ្យបាន ៨៧% និងសាលារៀនឱ្យបាន ១៥% ។

## IV.សេចក្តីសន្និដ្ឋាន

លទ្ធផលទាំងអស់ ដែលសម្រេចបានខាងលើនេះ ពិតជាបានឆ្លុះបញ្ចាំងនូវការខិតខំប្រឹងប្រែង ការប្តេជ្ញាចិត្តដ៏មុះមុតរបស់ថ្នាក់ដឹកនាំ បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ព្រមទាំងមានកិច្ចសហការយ៉ាងជិតស្និទ្ធរបស់គ្រប់អ្នកពាក់ព័ន្ធ ជាពិសេសដៃគូអភិវឌ្ឍវិស័យអប់រំដែលបានយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ផ្តោតលើក្រុមគោលដៅ ។ វិស័យអប់រំ យុវជន និងកីឡាខេត្តមានការប្រែប្រួលទាំងបរិមាណ និងគុណភាព។ ប៉ុន្តែយើងនៅតែមានបញ្ហាប្រឈមមួយចំនួនដូចជា ពង្រីកការអប់រំកុមារតូចអាយុ៥ឆ្នាំ ៤ឆ្នាំ ៣ឆ្នាំ ពង្រឹងការប្រមូលកុមារឱ្យចូលរៀន គុណភាពអប់រំនៅបឋមសិក្សា និងមធ្យមសិក្សា កុមារនៅក្រៅសាលារៀន ការបណ្តុះបណ្តាលជំនាញដល់យុវជនក្រៅសាលា ដែលត្រូវតែបន្តយកចិត្តទុកដាក់អនុវត្តវិធានការដោះស្រាយដែលបានលើកឡើង ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

## ឧបសម្ព័ន្ធទី១៖ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល នៃទិសដៅអាទិភាព ឆ្នាំ២០១៨-២០២០

| សូចនាករ | ជាក់ស្តែង 2016-2017 | ជាក់ស្តែង 2017-2018 | ចំណុចដៅ 2017-2018 | ស្ថានភាព |
|---|---|---|---|---|
| គោលនយោបាយទី១៖ ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់ | | | | |
| ១.ភាគរយកុមារអាយុ៥ឆ្នាំក្នុងការអប់រំកុមារតូចគ្រប់រូបភាព | 63.64% | 68.62% | 71% | → |
| ២.ចំនួនស្រុកដែលមានអត្រាត្រួតថ្នាក់នៅបឋមសិក្សាតិចជាង ឬស្មើ ៧% | 5 / 8 | 6 / 8 | 6 / 8 | ↑ |
| ៣.ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់មធ្យមសិក្សាបឋមភូមិយ៉ាងតិច ៨០% | 7 / 8 | 8 / 8 | 7 / 8 | ↑ |
| ៤.អត្រាអក្ខរកម្មជនពេញវ័យ (អាយុ ១៥ឆ្នាំឡើង) | 98.17% | 98.28% | 98.28% | ↑ |
| ៥.រង្វាយតម្លៃតេស្តស្តង់ដាថ្នាក់ខេត្តថ្នាក់ទី៣ មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា | | | | |
| ការអាន | n.a | មិនបានអនុវត្ត | 40% | ↓ |
| គណិតវិទ្យា | n.a | មិនបានអនុវត្ត | 40% | ↓ |
| ៦.ភាគរយគ្រូបឋមសិក្សាមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើង | 72% | 75% | 75% | ↑ |
| ៧.ភាគរយគ្រូកម្រិតមូលដ្ឋានមានសញ្ញាបត្របរិញ្ញាបត្រឡើង | 21% | 22.5% | 23% | → |
| គោលនយោបាយទី២ ៖ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | |
| ៨.ចំនួននាយកសាលាបានបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល | 39 | n.a | 45 | ↓ |
| ៩.ភាគរយនៃការទូទាត់ថវិកាប្រចាំឆ្នាំ | 97.8% | 97.6% | 98.1% | → |

សម្គាល់៖ ↑ សម្រេចចំណុចដៅ → លទ្ធផលអាចទទួលយកបាន ↓ មិនសម្រេចចំណុចដៅ

## ឧបសម្ព័ន្ធទី២៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំសិក្សា២០១៦-២០១៧

| អនុវិស័យ /ឆ្លងអនុវិស័យ | សកម្មភាព | ស្ថានភាព | សេចក្តីបញ្ជាក់ |
|---|---|---|---|
| ១.អនុវិស័យ | | | |
| ១.១ ការអប់រំកុមារតូច | -ប្រមូលកុមារចូលរៀនអាយុ ៥ឆ្នាំ ក្នុងកម្មវិធីអប់រំកុមារតូចគ្រប់រូបភាពឲ្យបាន៧៣%<br>-ប្រមូលកុមារចូលរៀនអាយុ ៤ឆ្នាំ ក្នុងកម្មវិធីអប់រំកុមារតូចគ្រប់រូបភាពឲ្យបាន៤០%<br>-ប្រមូលកុមារចូលរៀនអាយុ ៣ឆ្នាំ ក្នុងកម្មវិធីអប់រំកុមារតូចគ្រប់រូបភាពឲ្យបាន២២%<br>-បង្កើនភាគរយសេវាអប់រំកុមារតូចដែលបានអនុវត្តតេស្តទៀងទាត់ដើម្បីវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំជាទៀងទាត់ឲ្យបាន៨០%<br>-បង្កើនភាគរយកុមារក្នុងសេវាគាំពារ និងអភិវឌ្ឍកុមារតូចដែលមានស្ថានភាពអាហារូត្ថម្ភឲ្យបាន៦០%<br>-បង្កើនភាគរយកុមារនៅតាមសាលាមត្តេយ្យទទួលបានថ្នាំទំលាក់ព្រូនឲ្យបាន៩៥% | ១<br>១<br>១<br>១<br>១<br>១ | |
| ១.២.ការអប់រំបឋមសិក្សា | -បង្កើនភាគរយសាលាកុមារមេត្រីកម្រិតមធ្យមនិងកម្រិតអភិវឌ្ឍ៧០%<br>-បង្កើនអត្រាពិតចូលរៀនថ្មី ៩៨% ស្រី ៩៨%<br>-បង្កើនអត្រាពិតនៃការសិក្សា ៩៧% ស្រី ៩៨% | ១<br>១<br>១ | |

| | | | |
|---|---|---|---|
| | -កាត់បន្ថយអត្រាបោះបង់ការសិក្សា ២% ស្រី ២%<br>-កាត់បន្ថយអត្រាត្រួតថ្នាក់ ៥% ស្រី ៤%<br>-បង្កើនអត្រាបញ្ចប់ការសិក្សា ៩០% ស្រី ៩៣%<br>-បង្កើនភាគរយសិស្សថ្នាក់ទី១ ដែលបានឆ្លងកាត់មត្តេយ្យសិក្សា ៧២%<br>-បង្កើនអត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ ៩០%ស្រី ៩៤%<br>-បង្កើនភាគរយសាលាបឋមសិក្សាមានៈ<br>.បង្គន់អនាម័យ និងទឹកស្អាត៩៧%<br>.កន្លែងសម្អាតដៃ៤៨% | ១<br>១<br>១<br>១<br>១<br>១<br>១ | |
| ១.៣.ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស | -<br>កាត់បន្ថយអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ១១% ស្រី១០%<br>-<br>បង្កើនអត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ៦២%ស្រី ៦៨%<br>-<br>បង្កើនអត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ២៨%ស្រី ៣១%<br>-<br>បង្កើនអត្រាឆ្លងភូមិសិក្សាពីបឋមភូមិទៅទុតិយភូមិ៧៧%ស្រី៧៨%<br>-<br>បង្កើនអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ៤៩% ស្រី ៥៥%<br>-<br>បង្កើនភាគរយសាលាមធ្យមសិក្សាបឋមភូមិមានបង្គន់អនាម័យ៩៥%<br>-<br>បង្កើនចំនួនសិស្សក្នុងការអប់រំបច្ចេកទេស២២០នាក់ស្រី ៩៥នាក់<br>-<br>ចំនួនសិស្សពូកែប្រឡងថ្នាក់ជាតិទទួលបានជ័យលាភី ៦នាក់ ស្រី៣នាក់ | ១<br>១<br>១<br>១<br>១<br>១<br>១<br>១ | |
| ១.៤.អប់រំក្រៅប្រ | - | ១ | |

| | | | |
|---|---|---|---|
